ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## រដ្ឋបាលជលផល

ឯកសារស្រាវជ្រាវ

# ការផ្តល់

# សម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទ


រៀបរៀងដោយ :

សាស្ត្រាចារ្យបណ្ឌិត ណៅ ធួក "ប្រតិភូរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុកជា ប្រធានរដ្ឋបាលជលផល"

លោក សំ សត្យា "អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលនិងនីតិកម្ម"



ឧបត្ថម្ភដោយ :

អង្គការ សម្ព័ន្ធភាព ដើម្បីអភិរក្សជនជានជលផល(FACT)

ខែកញ្ញា ឆ្នាំ២០១២

# មាតិកា


**អារម្ភកថា** **ទំព័រ**

**សេចក្តីផ្តើម**............................................................................................១

**ជំពូកទី១: សញ្ញាណសម្បទានដីសេដ្ឋកិច្ចនិងដែននេសាទ**..............................៣

១-អំពីសម្បទានដីសេដ្ឋកិច្ច..........................................................................៣

ក-សញ្ញាណសម្បទានដីសេដ្ឋកិច្ច...................................................................៣

ខ-គោលបំណងសម្បទានដីសេដ្ឋកិច្ច...............................................................៣

គ-លក្ខណៈវិនិច្ឆ័យសម្រាប់ផ្តល់សម្បទានដីសេដ្ឋកិច្ច..........................................៤

២-អំពីដែននេសាទ......................................................................................៤

ក-សញ្ញាណដែននេសាទ...............................................................................៤

ខ-ការបែងចែកតំបន់គ្រប់គ្រងជលផលក្នុងដែននេសាទ........................................៥

គ-ដែននេសាទជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ............................................៧

ឃ-អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងដែននេសាទ...............................................១០

**ជំពូកទី២: នីតិវិធីផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទ**.........................១២

១-លក្ខណៈវិនិច្ឆ័យលើសំណើសម្បទានដីសេដ្ឋកិច្ច...........................................១២

២-នីតិវិធី.................................................................................................១២

ក-ការផ្តួចផ្តើមសម្បទានដីសេដ្ឋកិច្ច.................................................................១២

ខ-ការគ្រប់គ្រងនិងការកែប្រែកិច្ចសន្យាសម្បទាន..............................................១៩

គ-យន្តការរដ្ឋបាលនិងការអនុវត្តកិច្ចសន្យាសម្បទានសេដ្ឋកិច្ច .........................២០

ឃ-ការពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ..........................២៣

ង-កាតព្វកិច្ចសម្បទានិកនិងលក្ខខណ្ឌដកហូតដីសម្បទានសេដ្ឋកិច្ច....................២៦

**សន្និដ្ឋាន:**.............................................................................................២៨

**ឯកសារយោង:**..........................................................................................៣១

# អារម្ភកថា

សង្គ្រាមរាំរ៉ៃផ្ទៃក្នុងត្រូវបានបញ្ចប់តាមនយោបាយឈ្នះ-ឈ្នះរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ការកសាងនិងការអភិវឌ្ឍន៍ប្រទេសជាតិបាននិងកំពុងឈានទៅមុខជាលំដាប់លើគ្រប់វិស័យគួរឱ្យមោទនៈក្នុងនោះរួមទាំងវិស័យជលផលផងដែរ។

ដោយឡែក រចនាសម្ព័ន្ធគ្រប់គ្រងវិស័យជលផលត្រូវបានបង្កើតជាថ្មីឡើងវិញ តាំងពីឆ្នាំ១៩៨០ ដើម្បីគ្រប់គ្រងជលផលនិងធនធានជលផលប្រកបដោយនិរន្តរភាព។ វិស័យជលផលបានចូលរួមចំណែកជួយសម្រួលដល់ជីវភាពប្រជាពលរដ្ឋ អ្នកនេសាទ រៀបចំកន្លែងធ្វើនេសាទស្របតាមប្រភេទឧបករណ៍នេសាទ ដើម្បីចៀសវាងទំនាស់ផ្សេងៗ ដែលអាចកើតឡើងជាយថាហេតុ កាត់បន្ថយការធ្វើនេសាទហួសកម្រិត ថែរក្សាការពារព្រៃលិចទឹកនិងព្រៃកោងកាង កែលម្អដែននេសាទ ការពារជីវចម្រុះ បរិស្ថាន និងប្រព័ន្ធអេកូឡូស៊ីជលផល រៀបចំនិងការបង្កើតសហគមន៍នេសាទ ដើម្បីចូលរួមគ្រប់គ្រងនិងប្រើប្រាស់ធនធានជលផលប្រកបដោយនិរន្តរភាព អភិរក្សនិងអភិវឌ្ឍវារីវប្បកម្ម ចែកចាយផលនេសាទតាមតម្រូវការជូនប្រជាពលរដ្ឋទូទាំងប្រទេស ព្រមទាំងនាំចេញនិងប្រមូលថ្លៃឈ្នួលនេសាទលើឧបករណ៍នេសាទជាចំណូលថវិការដ្ឋស្របតាមផលស្តុកធម្មជាតិ ។

សម្រាប់ការអភិវឌ្ឍន៍នាសតវត្សទី២១ នេះ វិស័យជលផលបានចូលរួមចំណែកអភិវឌ្ឍប្រទេសជាតិថ្មីមួយទៀតតាមរយៈកម្មវិធីសម្បទានដីសេដ្ឋកិច្ចលើផ្នែកណាមួយនៃដែននេសាទដែលឈប់បម្រើវិស័យជលផល ហើយដែននេសាទនេះបានទៅបម្រើវិស័យផ្សេងវិញ។ បានសេចក្តីថា ដែននេសាទនោះត្រូវបានរិចរិលឬគោករីងរាក់ ហើយពុំអាចធ្វើការកែលម្អឬស្តារឡើងវិញបាន ប៉ុន្តែដែននេសាទនោះបានទៅបម្រើលើវិស័យផ្សេងទៅវិញជាអាទិ៍ ធ្វើស្រែចំការដាំដំណាំឬការសាងសង់លំនៅដ្ឋាន ឬសំណង់ផ្សេងៗ។ល។ ដូចនេះ ដែននេសាទទាំងនោះដាច់ខាតត្រូវបង្វែរទិសដៅប្រើប្រាស់ឱ្យបានចំទិសដៅតាមនីតិវិធីពោលគឺ អនុវត្តកម្មវិធីសម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទតាមរយៈការធ្វើអនុ-បយោគដែននេសាទមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ដើម្បីផ្តល់ជូនវិនិយោគិនធ្វើការអភិវឌ្ឍន៍។

ចំពោះនីតិវិធីនៃការធ្វើសម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទ ស្មេរនិពន្ធនឹងសិក្សាស្រាវជ្រាវរាវរកនូវឯកសារគតិយុត្តពាក់ព័ន្ធនានា ដើម្បីលើកយកមកលាតត្រដាងបញ្ជាក់ជូន ព្រមទាំងជាចំណងដៃជូនដល់មន្ត្រីរដ្ឋបាលជលផលគ្រប់ថ្នាក់ធ្វើជាមូលដ្ឋានគតិយុត្តក៏ដូចជាការការពារដែននេសាទជាទ្រព្យសម្បត្តិរបស់រដ្ឋបានគង់វង្ស ជាពិសេសរួចផុតពីការទន្ទ្រានកាន់កាប់ដែននេសាទដោយខុសច្បាប់ផងដែរ។

ការរៀបចំចងក្រងឯកសារស្រាវជ្រាវនេះ ស្មេរនិពន្ធសូមអភ័យទោសទុកជាមុនផងដែរ ចំពោះការអធិប្បាយពាក្យពេចន៍ឃ្លាឃ្លោង អក្ខរាវិរុទ្ធ ឬកិច្ចការស្រាវជ្រាវពុំទាន់បានគ្រប់គ្រាន់។ល។ ប៉ុន្តែស្មេរនិពន្ធសង្ឃឹមទុកជាមុនថាឯកសារស្រាវជ្រាវនេះ ពិតជានឹងផ្តល់ផលប្រយោជន៍តិចឬច្រើនជាក់ជាមិនខានឡើយ សម្រាប់ការគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានជលផលប្រកបដោយចីរភាពសម្រាប់កូនចៅជំនាន់ក្រោយរបស់យើង៕

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ ២០១២

## សេចក្តីផ្តើមៈ

ព្រះរាជាណាចក្រកម្ពុជាមានផ្ទៃដីសរុបចំនួន១៨១.០៣៥ គម² មានប្រជាពលរដ្ឋសរុបចំនួន១៤.០៨០.៦៥៣ នាក់ មានរាជធានីចំនួន១ ខេត្តចំនួន២៣ ស្រុក/ខណ្ឌចំនួន១៩៤ ឃុំ/សង្កាត់ចំនួន១.៦៣៣ និងភូមិចំនួន១៣.៨៨០ (ទិន្នន័យលេខន័ឆ្នាំ២០១២ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ)។

កម្ពុជា ជាប្រទេសមួយដែលសម្បូរទៅដោយធនធានធម្មជាតិនិងប្រាសាទបុរាណជាច្រើន ជាពិសេសដីប្រកបទៅដោយជីជាតិដែលបានបង្កលក្ខណៈងាយស្រួលដល់ប្រជាពលរដ្ឋកម្ពុជាក្នុងការបង្កបង្កើនផលដំណាំកសិកម្មជាច្រើនប្រភេទ។

ចំណុចសំខាន់មួយចំនួនក្នុងភូមិសាស្ត្រនៃប្រទេសកម្ពុជាដែលគួរឱ្យកត់សម្គាល់នោះរួមមាន តំបន់ភ្នំខ្ពស់ៗដែលស្ថិតនៅទិសនិរតីនៃប្រទេសគឺ ជួរភ្នំក្រវាញនិងតំបន់ភ្នំតូចៗ មួយចំនួនទៀតដែលតភ្ជាប់មួយផ្នែកពីជួរភ្នំក្រវាញឆ្ពោះទៅកាន់សមុទ្រនិងវាលទំនាបកណ្តាល។ តំបន់ទំនាបកណ្តាល ជាតំបន់ដីមានជីជាតិដែលអំណោយផលច្រើនទៅលើវិស័យកសិកម្មដែលមានក្រឡាផ្ទៃដី៦ លានហិកតា លាតសន្ធឹងជុំវិញបឹងទន្លេសាបដែលជាអតីតសមុទ្រទឹកសាប និងសម្បូរទៅដោយធនធានជលផល ជាពិសេសមច្ឆជាតិ។ បឹងទន្លេសាបនៅក្នុងរដូវប្រាំងមានផ្ទៃក្រឡាប្រមាណ ៣.០០០គម² និងនៅរដូវវស្សាមានផ្ទៃក្រឡាប្រមាណ១៦.០០០គម² ដែលជាផ្ទៃទឹកជំនន់ហូរមកពីទន្លេមេគង្គនិងតាមបណ្តាព្រែកឬស្ទឹងនានាដែលស្ថិតនៅជុំវិញបឹងទន្លេសាប។ បរិមាណត្រីដែលទឹកសាបដែលប្រមូលបានក្នុង១ ឆ្នាំគិតជាមធ្យមមានចំនួនចន្លោះពី៣៥០.០០០ តោនទៅ៥១៥.០០០ តោនក្នុងនោះ ផលចាប់តាមវាលស្រែមានចំនួន ១៤០.០០០ តោននិងវារីវប្បកម្មចំនួន៧២.០០០ តោន (វិទ្យាស្ថានស្រាវជ្រាវជលផលទឹកសាបឆ្នាំ២០១៣)ដែលបរិមាណនេះ ត្រូវបានចាត់ថ្នាក់ជាប្រទេសម្បូរត្រីទឹកសាបទី៤ ក្នុងចំណោមប្រទេសដែលសម្បូរត្រីទឹកសាបជាងគេក្នុងពិភពលោកគឺ ប្រទេសចិន ឥណ្ឌា និងប្រទេសបង់ក្លាដេស។ តាមឯកសារស្រាវជ្រាវបានបញ្ជាក់ថែមទៀតថា ប្រជាពលរដ្ឋកម្ពុជា ជាអ្នកចូលចិត្តបរិភោគត្រីច្រើនជាងគេដែលមានបរិមាណគិតជាមធ្យម៍ចំនួន៦៣ គីឡូក្រាម/ម្នាក់ក្នុង១ឆ្នាំ គិតជាតិប្រូតេអ៊ីនសរុបដែល ប្រើប្រាស់សម្រាប់ជាម្ហូបអាហារប្រជាពលរដ្ឋកម្ពុជាទទួលបានជាតិប្រូតេអ៊ីនពីសាច់ត្រីចំនួន៨១,៥%។

ចំពោះតំបន់សមុទ្រវិញ ព្រះរាជាណាចក្រកម្ពុជាមានឆ្នេរសមុទ្រសរុបប្រវែង៤៣៥ គីឡូម៉ែត្រ ហើយសម្បូរទៅដោយមច្ឆជាតិ ផ្កាថ្ម ស្មៅសមុទ្រ ជាពិសេសព្រៃកោងកាងតាមបណ្តោយឆ្នេរដែលជាជម្រកសម្រាប់ជាកន្លែងរស់នៅរបស់មច្ឆជាតិ ប្រភពផ្តល់ចំណី និងជាកន្លែងពងកូនដ៏សំខាន់របស់មច្ឆជាតិផងដែរ។ ប៉ុន្តែជាអកុសលភាពសម្បូរសប្បាយគួរឱ្យមោទនៈនេះ ត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាមផ្ទៃក្នុងអស់ជាច្រើនទស្សវត្សរហូតដល់ចុងទស្សវត្សឆ្នាំ ៩០ ទើបមានការបង្រួបបង្រួមនិងផ្សះផ្សាជាតិឡើងវិញ តាមរយៈនយោបាយឈ្នះ-ឈ្នះរបស់**សម្តេចអគ្គមហា**

**សេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**។ សង្គ្រាមត្រូវបានបញ្ចប់ ការកសាងនិងការអភិវឌ្ឍប្រទេសជាតិ បានចាប់ផ្តើមតាមរយៈការបើកទូលាយដល់វិនិយោគិនជាតិនិងអន្តរជាតិលើគ្រប់វិស័យក្នុងនោះ រួមទាំងការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងដែននេសាទផងដែរ។

ការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទ គឺអនុញ្ញាតឱ្យសម្បទានិកឬអ្នកទទួលប្រយោជន៍កាប់ឆ្ការទាញយកផលដោយធ្វើអាជីវកម្មកសិ-ឧស្សាហកម្មនៅក្នុងផ្នែកណាមួយនៃដែននេសាទដែលឈប់បម្រើវិស័យជលផលឬផលប្រយោជន៍សាធារណៈ។ ប៉ុន្តែដែននេសាទអាចអនុវត្តកម្មវិធីសម្បទានដីសេដ្ឋកិច្ចបាន លុះត្រាតែធ្វើអនុបយោគដែននេសាទនេះ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាមុនសិន ទើបអនុវត្តកម្មវិធីសម្បទានដីសេដ្ឋកិច្ចបាន (មាត្រា ១៦ នៃនីតិភូមិបាលឆ្នាំ២០០១)។ បានសេចក្តីថា ដែននេសាទដែលអាចធ្វើសម្បទានសេដ្ឋកិច្ចបានលុះត្រាតែក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានសិក្សាវាយតម្លៃថា ដែននេសាទនេះបានគោករីករាក់ហើយមិនអាចស្តារឡើងវិញបានទេ និយាយរួមដែននេសាទនេះឈប់បម្រើវិស័យជលផលទៀតហើយ ហើយបានទៅបម្រើវិស័យផ្សេងទៀត។ ដូចនេះ រាជរដ្ឋាភិបាលត្រូវប្តូរទ្រព្យនេះទៅបម្រើលើវិស័យផ្សេងទៀតតាមការជាក់ស្តែង។

ចំពោះសម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទ តាមបញ្ញត្តិនៃនីតិភូមិបាលឆ្នាំ២០០១ សម្បទានិកមានសិទ្ធិនៅលើដីធ្លីមានរយៈពេលកំណត់៩៩ ឆ្នាំតាមកិច្ចសន្យាដែលបានបង្កើតសម្បទាន ប៉ុន្តែមិនអាចឈានដល់ការបង្កើតសិទ្ធិជាកម្មសិទ្ធិដែលបានផ្តល់សម្បទានបានទេ។ ម្យ៉ាងទៀត សម្បទានដីសេដ្ឋកិច្ចក៏មិនអាចកើតចេញពីស្ថានភាពកាន់កាប់ដីជាក់ស្តែងបានដែរ។ សម្បទានដីសេដ្ឋកិច្ច ដាច់ខាតត្រូវតែមានសំអាងនូវលិខិតគតិយុត្តជាក់លាក់ដែលបានផ្តល់មុនការចូលកាន់កាប់ដីធ្លីនោះដោយអាជ្ញាធរសាធារណៈដែលជាម្ចាស់ដីធ្លី (មាត្រា៥២ មាត្រា៥៣ និងមាត្រា៦១ នៃនីតិភូមិបាលឆ្នាំ២០០១)។

ការសិក្សាស្រាវជ្រាវនេះ ដើម្បីស្វែងរកបណ្តាវិធានគតិយុត្តទាំងឡាយដែលពាក់ព័ន្ធនិងនីតិវិធីជាធរមានក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងដែននេសាទ។ បន្ទាប់មក ស្នេរនិពន្ធនឹងលើកយកមកលាតត្រដាងបញ្ជាក់ជូនដល់មិត្តអ្នកអានដែលមានបំណងស្វែងយល់ជុំវិញបញ្ហាសម្បទានដីសេដ្ឋកិច្ច ជាពិសេសជាឯកសារជូនដល់មន្ត្រីរដ្ឋបាលជលផលថ្នាក់មូលដ្ឋានទាំងអស់ ដើម្បីចូលរួមការពារ ថែរក្សា និងគ្រប់គ្រងដែននេសាទនិងធនធានជលផលប្រកបដោយនិរន្តរភាពសម្រាប់កូនចៅគ្រប់ជំនាន់ក៏ដូចជាការចូលរួមផ្តល់ស្ថេរភាព សុវត្ថិភាពគតិយុត្តជូនសម្បទានិកដែលត្រូវបានផ្តល់ដីធ្វើសម្បទានសេដ្ឋកិច្ចក្នុងដែននេសាទផងដែរ។

សញ្ញាណសម្បទានដីសេដ្ឋកិច្ចនិងដែននេសាទ ស្នេរនិពន្ធនឹងលើកយកមកពិភាក្សាក្នុងជំពូកទី១ បន្ទាប់មក នីតិវិធីនៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចក្នុងដែននេសាទ ត្រូវបានលើកយកមកបញ្ជាក់ជូនក្នុងជំពូកទី២ បន្ទាប់៕

## ជំពូកទី១: សញ្ញាណសម្បទានដីសេដ្ឋកិច្ចនិងដែននេសាទ

### ១-អំពីសម្បទានដីសេដ្ឋកិច្ច

### ក- សញ្ញាណសម្បទានដីសេដ្ឋកិច្ច

តើអ្វីទៅសម្បទានដីសេដ្ឋកិច្ច? សម្បទានដីសេដ្ឋកិច្ចគឺ សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋតាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឱ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្មនិងកសិ-ឧស្សាហកម្ម។ ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្មគឺ សំដៅដល់៖

-ការដាំដំណាំស្បៀងឬដំណាំឧស្សាហកម្មរាប់ទាំងការដាំដើមឈើ ចំការឈើ

-ការចិញ្ចឹមសត្វនិងវារីវប្បកម្ម

-ការងារសាងសង់ដូចជា រោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសម្រាប់កែច្នៃវត្ថុធាតុដើមដែលជាកសិផលក្នុងស្រុកឬ

-សកម្មភាពរួមគ្នានៃសកម្មភាពមួយចំនួនឬទាំងអស់ដែលបានរៀបរាប់ខាងលើ (មាត្រា២ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

### ខ- គោលបំណងសម្បទានដីសេដ្ឋកិច្ច

សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តល់ឱ្យក្នុងគោលបំណងដូចខាងក្រោម៖

-អភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្មនិងកសិ-ឧស្សាហកម្មដែលតម្រូវឱ្យមានការវិនិយោគដើមទុនដំបូងក្នុងអត្រាខ្ពស់និងកម្រិតសមស្រប

-សម្រេចបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពីអ្នកវិនិយោគសម្រាប់ការអភិវឌ្ឍដីក្នុងលក្ខណៈសមស្របនិងប្រកបដោយចីរភាពដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់នោះ

-បង្កើតភាពមានការងារធ្វើនៅជនបទក្នុងក្របខណ្ឌនៃការធ្វើប្រពលវប្បកម្មនិងការធ្វើឱ្យមានកាលានុវត្តភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសម្បូរបែបនិងក្នុងក្របខណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិតាមប្រព័ន្ធអេកូឡូស៊ីសមស្រប

-លើកទឹកចិត្តរាល់ការវិនិយោគក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច

-បង្កើតចំណូលរដ្ឋឬចំណូលរាជធានី/ខេត្ត ឃុំ/សង្កាត់ តាមការប្រមូលថ្លៃប្រើប្រាស់ដី ពន្ធ និងកម្រៃសេវាពាក់ព័ន្ធ (មាត្រា៣ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)និង

-បង្កើតការងារជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋានឱ្យមានការងារធ្វើកាន់តែច្រើនថែមទៀតតាមការរីកចម្រើន

នៃសេដ្ឋកិច្ចជាតិនិងសង្គម។

**គ- លក្ខណៈវិនិច្ឆ័យសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច**

សម្បទានដីសេដ្ឋកិច្ច អាចប្រព្រឹត្តទៅបានលុះត្រាដីនោះមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

១-ដីដែលបានចុះបញ្ជីនិងធ្វើចំណាត់ថ្នាក់ថាជាដីឯកជនរបស់រដ្ឋស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគល់បញ្ជីដីធ្លីឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ។

២-ដីដែលមានផែនការប្រើប្រាស់ ដីអនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ហើយការប្រើប្រាស់មានលក្ខណៈស្របតាមផែនការនោះ។

៣-ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម ចំពោះការប្រើប្រាស់និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន។

៤-ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមក្របខណ្ឌគតិយុត្តនិងនីតិវិធីជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថា មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញ ចូលទៅកាន់ដីឯកជន។

៥-ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោងឬសំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដីនិងប្រជាពលរដ្ឋនៅក្នុងតំបន់។

ចំពោះការវាយតម្លៃលើសំណើសម្បទានដីសេដ្ឋកិច្ច ត្រូវធ្វើការវិនិច្ឆ័យដូចខាងក្រោម៖

-ការបង្កើនផលិតផលកសិកម្មនិងកសិ-ឧស្សាហកម្ម ដោយប្រើប្រាស់បច្ចេកទេសទំនើប

-ការបង្កើតឱ្យមានការងារធ្វើកាន់តែច្រើន

-ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

-ការការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

-ការចៀសវាងឬការកាត់បន្ថយឱ្យនៅតិចបំផុតនូវហេតុប៉ះពាល់ជាអវិជ្ជមានដល់សង្គម

-ការផ្សារភ្ជាប់និងការគាំទ្រទៅវិញទៅមករវាងដីសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ចប្រសិនបើមាននិង

-ការកែច្នៃវត្ថុធាតុដើមជាកសិផលដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាសម្បទាន។

## ២-អំពីដែននេសាទ

**ក- សញ្ញាណដែននេសាទ**

ដែននេសាទរួមមាន៖ ដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទនិងការការពារប្រព័ន្ធអេកូឡូស៊ីជលផលក្នុងនោះរួមមាន៖

-ដែនដីលិចទឹកអចិន្ត្រៃយ៍មានជាអាទិ៍ សមុទ្រ ទន្លេ ដៃទន្លេ បឹង ព្រែក ស្ទឹង អូរ អាងទឹក និងប្រឡាយ

-ដែនដីដែលទទួលរបបទឹកទន្លេមេគង្គមានជាអាទិ៍ ត្រពាំង រណ្តៅ វាលភក់ ល្បាប់ វាលទំនាបដែលលិចទឹកក្នុងរដូវទឹកជំនោរនិងនាទីព្រៃលិចទឹក

-ដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រមានជាអាទិ៍ នាទីព្រៃកោងកាង (មាត្រា៨ នៃនីតិជលផល)។

មានន័យថា ដែនដីដែលលិចទឹកអចិន្ត្រៃយ៍ឬដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរ នាចនៃសមុទ្រទាំងនោះ ត្រូវមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទនិងការការពារនូវប្រព័ន្ធអេកូឡូស៊ីជលផល និងការកំណត់ព្រំប្រទល់ដែននេសាទជាក់លាក់ផងដែរ។ ប៉ុន្តែបញ្ហាដែននេសាទកន្លងមក តែងមានការបកស្រាយជាទូទៅថា ទឹកឡើងឬជោរដល់ណាគឺ ដែននេសាទដល់ត្រឹមនោះ។ ផ្ទុយទៅវិញ ការបកស្រាយនេះគឺមិនត្រឹមត្រូវតាមបញ្ញត្តិនៃនីតិជលផលឆ្នាំ២០០៦ ទេ មានន័យថា ដែននេសាទមានការកំណត់ព្រំប្រទល់ច្បាស់លាស់។ ជាក់ស្តែង មាត្រា៩ នៃនីតិជលផលបានបញ្ញត្តិថាៈ"*ព្រំប្រទល់ដែននេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ* "។ ប៉ុន្តែរហូតមកដល់បច្ចុប្បន្ន អនុក្រឹត្យស្តីពីការកំណត់ព្រំប្រទល់ដែននេសាទគឺ ស្ថិតនៅក្នុងដំណាក់កាលជាសេចក្តីព្រាងនៅឡើយ។ ដោយឡែក កថាខណ្ឌទី៣ មាត្រា៩ នៃនីតិជលផលដដែលបានបញ្ញត្តិទៀតថាៈ"*ដែននេសាទ អាចគ្របដណ្តប់លើដីសាធារណៈឬដីកម្មសិទ្ធិឯកជននារដូវជំនោរឡើង ប៉ុន្តែការគ្រប់គ្រងជលផលមិនប៉ះពាល់ដល់ដីកម្មសិទ្ធិទាំងនោះឡើយ*"។

ចំពោះការបញ្ញត្តិនេះ និពន្ធនីតិជលផលឆ្នាំ២០០៦ មានគោលបំណងពន្លាតសមត្ថកិច្ចរបស់ខ្លួនឱ្យបានស្របច្បាប់ក្នុងការត្រួតពិនិត្យនិងបង្ក្រាបបទល្មើសជលផលគ្រប់ប្រភេទដែលអាចកើតឡើងលើដីកម្មសិទ្ធិឯកជន។ ប៉ុន្តែទោះបីជាពុំមានចែងយ៉ាងនេះក៏ដោយ ក៏មន្ត្រីនគរបាលយុត្តិធម៌ជលផលនៅតែមានសិទ្ធិស្របច្បាប់ក្នុងការស្រាវជ្រាវត្រួតពិនិត្យ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌទាំងនោះបានដែរដោយហេតុថា បញ្ហាព្រហ្មទណ្ឌគឺ ជាបញ្ហារួមរបស់សង្គមទាំងមូល។ ដូចនេះ ចាំបាច់តម្រូវឱ្យរដ្ឋាភិបាលរៀបចំដាក់ចេញនូវបទប្បញ្ញត្តិផ្សេងៗ ដើម្បីហាមឃាត់និងទប់ស្កាត់អំពើទាំងនោះកុំឱ្យកើតមានឡើង។ ផ្ទុយទៅវិញ ករណីមានជនណាមួយបានប្រព្រឹត្តិផ្ទុយទៅនឹងបទប្បញ្ញត្តិហាមឃាត់គឺ ជននោះត្រូវតែទទួលរងនូវទណ្ឌកម្មទៅតាមទំហំកំហុសដែលគេបានប្រព្រឹត្ត។ រីឯអ្នកដែលមានភារកិច្ចរឿងព្រហ្មទណ្ឌវិញគឺ នគរបាលយុត្តិធម៌និងចៅក្រម។ មាត្រា៧២ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ជាក់ថា បទល្មើសជលផលជា <u>**បទល្មើសព្រហ្មទណ្ឌ**</u>។ តាមគោលការណ៍ បទល្មើសព្រហ្មទណ្ឌទោះបីជាកើតឡើងនៅទីណាក៏ដោយក៏នគរបាលយុត្តិធម៌មានសិទ្ធិស្របច្បាប់ក្នុងការស្រាវជ្រាវ ទប់ស្កាត់ ត្រួតពិនិត្យ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌនោះចាត់ការតាមនីតិវិធីដែរ។ ជាក់ស្តែង មាត្រា១២ ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ២០០៩ បានបញ្ញត្តិថាៈ "*ក្នុងរឿងព្រហ្មទណ្ឌ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយដែលបានប្រព្រឹត្តនៅលើដែនដីនៃព្រះរាជាណាចក្រកម្ពុជា*"។

**ខ- ការបែងចែកតំបន់គ្រប់គ្រងជលផលក្នុងដែននេសាទ**

ដែននេសាទត្រូវបានបែងចែកជា ដែននេសាទទឹកសាបនិងដែននេសាទសមុទ្រ។

**ខ-១-ដែននេសាទទឹកសាប**

ដែននេសាទទឹកសាប គឺជាផ្ទៃទឹកដែលលាតសន្ធឹងចាប់ពីដែននេសាទសមុទ្ររហូតដល់ព្រំប្រទល់ដីគោកនៃព្រះរាជាណាចក្រកម្ពុជា។ ដែននេសាទទឹកសាបរួមមានៈ

-ឡូត៍នេសាទដែលទុកសម្រាប់សម្បទានដល់ការវិនិយោគឬជួលឱ្យធ្វើអាជីវកម្ម។ ឡូត៍នេសាទ សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាប ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់ដែលមានប្រព័ន្ធបឹងព្រែក ព្រៃលិចទឹក ធនធានជលផលនិងជីវចម្រុះដែលកំណត់នូវការកកើត និងការរីកធំធាត់របស់មច្ឆជាតិ វារីសត្វ និងវារីរុក្ខជាតិ ព្រមទាំងកំណត់ទីតាំងនិងពេលវេលាធ្វើអាជីវកម្មជាក់លាក់ដោយមិនជះឥទ្ធិពលដល់ទីតាំងផ្សេងទៀត

-កន្លែងអភិរក្សជលផលដែលជាជម្រករក្សាពូជវារីសត្វនិងវារីរុក្ខជាតិ។ កន្លែងអភិរក្សជលផល សំដៅដល់ចំណាត់ថ្នាក់នៃដែននេសាទទឹកសាបឬសមុទ្រ ហើយត្រូវបានកំណត់ភូមិសាស្ត្រជាក់លាក់សម្រាប់វារីសត្វឬ រុក្ខជាតិជ្រកពួន ពងកូន រីកធំធាត់ឬរីកលូតលាស់។ កន្លែងអភិរក្សជលផល ជាថ្នាលពូជនិងជាតំបន់ការពារធនធានជលផល ហើយពុំអនុញ្ញាតឱ្យប្រព្រឹត្តសកម្មភាពណាមួយដែលអាចនាំឱ្យមានផលប៉ះពាល់ដល់ធនធានជលផលក្រៅពីការសិក្សាស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផលស្របតាមគោលការណ៍ត្រឹមត្រូវ (ឧបសម្ព័ន្ធនៃនីតិជលផល)

-នាទីព្រៃលិចទឹករួមមានៈ តំបន់ព្រៃទឹកលិចដែលជាជម្រកចាំបាច់របស់វារីសត្វក្នុងការស្វែងរកចំណីឬកន្លែងពងកូននិងតំបន់លិចទឹកដែលត្រូវការពារ។ នាទីព្រៃលិចទឹក សំដៅដល់ផ្ទៃដីលិចទឹកដោយរបបទឹកទន្លេមេគង្គឬដីលិចទឹកដោយរបបទឹកជោរ នាចរបស់សមុទ្រដែលគ្របដណ្តប់ដោយព្រៃលិចទឹកនិងព្រៃកោងកាង។ នាទីព្រៃលិចទឹកនិងព្រៃកោងកាងរាប់បញ្ចូលទាំងតំបន់លិចទឹកដែលត្រូវការពារ (ឧបសម្ព័ន្ធនៃនីតិជលផល)។

ចំពោះតំបន់លិចទឹកដែលត្រូវការពាររួមមានៈ ដីលិចទឹកដែលស្ថិតនៅក្នុងនាទីឡូត៍នេសាទនិងស្ថិតនៅក្នុងនាទីព្រៃលិចទឹកនិងព្រៃកោងកាងដែលត្រូវការពារសម្រាប់ដាំឬរក្សាទុកឱ្យដុះព្រៃឡើងវិញ ដើម្បីរក្សាលំនឹងប្រព័ន្ធអេកូឡូស៊ីជលផល (មាត្រា២៧ នៃនីតិជលផល)។

-កន្លែងនេសាទគ្រួសារដែលរក្សាទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាប្រពៃណីឬសហគមន៍ធ្វើនេសាទ

-កន្លែងនេសាទបម្រុង ជាកន្លែងនេសាទទាំងឡាយដែលពុំបានធ្វើការចាត់ថ្នាក់។ កន្លែងនេសាទបម្រុងសំដៅដល់ផ្នែកមួយនៃដែននេសាទទឹកសាបដែលមិនមែនឡូត៍នេសាទ កន្លែងអភិរក្សជលផល នាទីព្រៃលិចទឹក កន្លែងនេសាទគ្រួសារ ឬទំនាបលិចទឹកក្នុងរដូវទឹកជំនើ។ កន្លែងនេសាទបម្រុងមិនត្រូវបានធ្វើការចាត់ថ្នាក់ជាតំបន់គ្រប់គ្រងជលផលជាក់លាក់ឡើយ ហើយត្រូវបានអនុញ្ញាតឱ្យធ្វើនេសាទបានតែការនេសាទ២ ប្រភេទគឺៈ ការនេសាទជាលក្ខណៈគ្រួសារនិងការធ្វើនេសាទជាលក្ខណៈសិប្បកម្ម។ ចំពោះកន្លែងនេសាទបម្រុងរួមមានៈ ទន្លេ ស្ទឹង ព្រែក បឹង អាងធម្មជាតិ ឬត្រពាំង។ល។

-កន្លែងនេសាទសម្រាប់អភិវឌ្ឍវារីវប្បកម្ម

-ទំនាបលិចទឹកក្នុងរដូវជំនើ។ ទំនាបលិចទឹកនៅរដូវជំនើ សំដៅដល់ដីទំនាបដែលទទួលរបបទឹកទន្លេ

មេគង្គដែលមិនមែនជាទីតាំងឡូត៍នេសាទ ព្រៃលិចទឹក កន្លែងអភិរក្សជលផល កន្លែងនេសាទគ្រួសារ និងកន្លែងនេសាទបម្រុងរួមមាន៖ វាលទំនាប វាលស្មៅ វាលស្រែចំការ និងដីដែលទឹកទន្លេមេគង្គឡើងដល់ ហើយដែលជាទីវាលទំនាបដ៏សំខាន់សម្រាប់មច្ឆជាតិធ្វើចរាចរណ៍រកកន្លែងពងកូននិងស្វែងរកចំណីនៅក្នុងរដូវបិទនេសាទ (មាត្រា១០ នៃនីតិជលផលនិងឧបសម្ព័ន្ធ)។

**ខ-២-ដែននេសាទសមុទ្រ**

ដែននេសាទសមុទ្រគឺ ជាផ្ទៃទឹកសមុទ្រឬទឹកភ្លាវដែលលាតសន្ធឹងពីខ្សែបន្ទាត់ដែលទឹកជោរខ្ពស់បំផុតនៃតំបន់ឆ្នេររហូតដល់ព្រំប្រទល់ខាងក្រៅ នៃដែនសមុទ្រតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា។ ដែននេសាទសមុទ្រត្រូវបានចែកជា៖

-កន្លែងនេសាទតាមឆ្នេរ ដែលលាតសន្ធឹងពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតរហូតដល់ខ្សែបន្ទាត់ដែលមានជម្រៅទឹកម្ភៃ(២០) ម៉ែត្រ

-កន្លែងនេសាទសមុទ្រខាងក្រៅដែលលាតសន្ធឹងពីខ្សែបន្ទាត់ដែលមានជម្រៅទឹកម្ភៃ(២០) ម៉ែត្ររហូតដល់ព្រំប្រទល់ខាងក្រៅនៃដែនសមុទ្រតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់ព្រះរាជាណាចក្រកម្ពុជា

-កន្លែងអភិរក្សជលផល តំបន់ស្មៅសមុទ្រ និងតំបន់ផ្កាថ្មជាជម្រករក្សាពូជវារីសត្វនិងវារីរុក្ខជាតិ

-នាទីព្រៃកោងកាងរួមមាន តំបន់ព្រៃកោងកាងនិងព្រៃទាំងអស់ដែលជាជម្រកចាំបាច់របស់វារីសត្វក្នុងការស្វែងរកចំណីឬកន្លែងពងកូននិងតំបន់លិចទឹកដែលត្រូវការពារ (មាត្រា១១ នៃនីតិជលផល)។

ចំពោះទ្រព្យសម្បត្តិរបស់រដ្ឋ នីតិភូមិបាលឆ្នាំ២០០១ បានកំណត់ជាក់លាក់ថា ទ្រព្យសម្បត្តិរបស់រដ្ឋមាន២ ប្រភេទគឺ៖ ទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនិងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ហើយទ្រព្យសម្បត្តិរបស់រដ្ឋទាំង២ នេះមានរបបគតិយុត្តសម្រាប់ធ្វើការគ្រប់គ្រងនិងការចាត់ចែងទ្រព្យមិនដូចគ្នាទេ។ ផ្ទុយទៅវិញ នីតិជលផលឆ្នាំ២០០៦ ពុំបានបញ្ជាក់ឱ្យបានច្បាស់ថា តើដែននេសាទជាទ្រព្យសម្បត្តិណាមួយរបស់រដ្ឋនោះទេ។ បញ្ហានេះ ស្នេរនិពន្ធនឹងសិក្សាស្រាវជ្រាវរកឱ្យឃើញថា តើដែននេសាទជាទ្រព្យសម្បត្តិណាមួយរបស់រដ្ឋ ? ដោយផ្អែកតាមសម្មតិកម្មគតិយុត្ត និងគោលការណ៍នីតិរដ្ឋបាលនៃទ្រព្យសម្បត្តិសាធារណៈ។

**គ- ដែននេសាទជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ**

មាត្រា១៤ នៃនីតិភូមិបាលឆ្នាំ២០០១ បានធ្វើការបែងចែកទ្រព្យសម្បត្តិរបស់រដ្ឋ២ ប្រភេទគឺ៖ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ។ ចំពោះទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ជាគោលការណ៍ទ្រព្យសម្បត្តិនេះត្រូវបានដាក់ឱ្យស្ថិតនៅក្រោមរបបគតិយុត្តពិសេសនិងមិនអាចលក់ដូរបានទេ។ម្យ៉ាងទៀត ទ្រព្យនេះគ្មានការកំណត់អាជ្ញាយុកាលទេ។ មានន័យថា ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនៅតែជាទ្រព្យសម្បត្តិរបស់រដ្ឋជា

រៀងរហូត។ ប៉ុន្តែទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ អាចជាកម្មវត្ថុនៃការអនុញ្ញាតឱ្យកាន់កាប់ឬប្រើប្រាស់ជាបណ្តោះអាសន្ន មិនទៀង ហើយអាចដកហូតវិញបានបើមិនបានបំពេញកាតព្វកិច្ចបង់ពន្ធផ្សេងៗ (មាត្រា១៦ នៃនីតិភូមិបាលឆ្នាំ២០០១)។ ចំណែកទ្រព្យសម្បត្តិឯកជនរបស់រដ្ឋវិញ គឺជាទ្រព្យសម្បត្តិដែលរដ្ឋបានធ្វើការគ្រប់គ្រងដូចទ្រព្យកម្មសិទ្ធិឯកជនដែរ ហើយទ្រព្យសម្បត្តិនេះ ក៏អាចជាកម្មវត្ថុ នៃកិច្ចការជំនួញឬអាចបែងចែកទៅឱ្យបុគ្គលក្នុងគោលការណ៍សង្គមកិច្ច ដើម្បីអនុញ្ញាតឱ្យបុគ្គលនោះរៀបចំសាងសង់លំនៅឋានឬ/និងដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋសម្រាប់ធានាការចិញ្ចឹមជីវិត (មាត្រា១៧ និងមាត្រា៤៩ នៃនីតិភូមិបាលឆ្នាំ២០០១)។

**គ-១-សម្មតិកម្មគតិយុត្តនៃនីតិភូមិបាលឆ្នាំ២០០១**

ផ្អែកតាមសម្មតិកម្មគតិយុត្តមាត្រា១៥ នៃនីតិភូមិបាលឆ្នាំ២០០១ បានបញ្ញត្តិថា៖" *រាប់ចូលក្នុងទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ៖*

*-ទ្រព្យទាំងឡាយណាដែលបង្ហាញនូវការកើតឡើងពីធម្មជាតិដូចជា ព្រៃឈើ ផ្លូវទឹក...បឹងធម្មជាតិ...*

*-ទ្រព្យទាំងឡាយណាដែលជាកម្មវត្ថុនៃការរៀបចំពិសេសសម្រាប់បម្រើប្រយោជន៍ទូទៅដូចជា...កំពង់ផែ ផ្លូវដែក ស្ថានីយរថភ្លើង និងព្រលានយន្តហោះ*

*-ទ្រព្យទាំងឡាយណាដែលត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈតាមស្ថានភាពពីកំណើតឬក្រោយពីបានរៀបចំដូចជា ផ្លូវថ្នល់ ផ្លូវលំ ផ្លូវរទេះ ផ្លូវដើរ សួនច្បារ និងឧទ្យានសាធារណៈនិងដីចំណី*

*-ទ្រព្យទាំងឡាយដែលត្រូវបានដាក់ឱ្យដំណើរការសម្រាប់សេវាសាធារណៈដូចជា សាលារៀនឬអគារសិក្សាសាធារណៈ អគាររដ្ឋបាល មន្ទីរពេទ្យសាធារណៈទាំងឡាយ។*

-........................................................................................................"។

តាមសម្មតិកម្មគតិយុត្តមាត្រា១៥ នៃនីតិភូមិបាលឆ្នាំ២០០១ និងមាត្រា៨ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ជាក់ថា ដែននេសាទជាដែនដីលិចទឹកអចិន្ត្រៃយ៍ ដែនដីដែលទទួលរបបទឹកទន្លេមេគង្គ និងដែនដីដែលទទួលរបបទឹកជោរនាចនៃសមុទ្រដែលមានតួនាទីសំខាន់បម្រើឱ្យការនេសាទគ្រប់ប្រភេទនិងការការពារប្រព័ន្ធអេកូឡូស៊ីជលផលហើយដែលកើតឡើងពីធម្មជាតិ។ ដូចនេះ ដែននេសាទគឺជា **ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ**។

**គ-២-សម្មតិកម្មគតិយុត្តក្រោមនីតិជលផលឆ្នាំ២០០៦**

កំឡុងឆ្នាំ១៩៩៨ នៅព្រះរាជាណាចក្រកម្ពុជាបានរៀបចំនិងបង្កើតសហគមន៍នេសាទជាដំបូងនៅតាមបណ្តាខេត្តមួយចំនួនជាអាទិ៍ ខេត្តស្ទឹងត្រែង ក្រចេះ ស្វាយរៀង និងខេត្តសៀមរាប។ ប៉ុន្តែការរៀបចំបង្កើតសហគមន៍នេសាទនេះ គឺអនុវត្តដោយអង្គការមិនមែនរដ្ឋាភិបាលដែលទទួលបានបទពិសោធន៍ពីបណ្តាប្រទេសនានាក្នុងគោលបំណងធ្វើការសាកល្បងតែប៉ុណ្ណោះ គឺពុំមានការគាំទ្រផ្អែកគតិយុត្តឡើយ។ បន្ទាប់មក នៅចុងឆ្នាំ២០០០ ការរៀបចំបង្កើតសហគន៍នេសាទត្រូវបានធ្វើឡើងយ៉ាងទូលំទូលាយនៅទូទាំងព្រះរាជាណាចក្រកម្ពុជាតាមរយៈព្រះរាជក្រឹត្យ

លេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី២៩ខែឧសភា ឆ្នាំ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ ដើម្បីបើកផ្លូវឈានទៅបង្កើតសហគមន៍នេសាទឱ្យបានស្របច្បាប់។ ជាក់ស្តែង មាត្រា៣ នៃព្រះរាជក្រឹត្យបានបញ្ញត្តិថាៈ" ***វិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទ ត្រូវកំណត់ដោយអនុក្រឹត្យ*** "។ អនុលោមតាមបទប្បញ្ញត្តិនេះ អនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទត្រូវបានរៀបចំនិងអនុម័តដាក់ឱ្យអនុវត្តជាផ្លូវការ ដើម្បីផ្តល់និត្យានុកូលភាពជូនសហគមន៍នេសាទ។ ក្រោយមក អនុក្រឹត្យលេខ ៨០ អនក្រ.បក ក៏ត្រូវបានធ្វើវិសោធនកម្មដោយជំនួសមកវិញនូវអនុក្រឹត្យលេខ ២៥ អនក្រ.បក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៧។ មាត្រា៣ នៃអនុក្រឹត្យលេខ ២៥ ក្រោយបានបញ្ញត្តិថាៈ"***កន្លែងនេសាទសហគមន៍គឺ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ*** ។ " ដូចនេះ ដែននេសាទគឺ ជា**ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ** ដោយហេតុថា កន្លែងនេសាទសហគមន៍ស្ថិតនៅក្នុងដែននេសាទ (មាត្រា១០ និងមាត្រា១១ នៃនីតិជលផលឆ្នាំ២០០៦)។

**គ-៣-សម្មតិកម្មដោយផ្អែកតាមគោលការណ៍**

តាមគោលការណ៍នីតិរដ្ឋបាលនៃទ្រព្យសម្បត្តិសាធារណៈ ការចាត់ទុកទ្រព្យណាមួយជាទ្រព្យសម្បត្តិសាធារណៈត្រូវបានពិនិត្យលើសមាសភាពនៃទ្រព្យសម្បត្តិ (១) របបគតិយុត្តគ្រប់គ្រងទ្រព្យសម្បត្តិ (២) និងការប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះ (៣)។

(១)-អំពីសមាសភាពនៃទ្រព្យសម្បត្តិសាធារណៈ៖ តាមគោលការណ៍នេះ ការចាត់ទុកជាទ្រព្យសម្បត្តិសាធារណៈបាន គេបានធ្វើការបែងចែកទ្រព្យនោះទៅតាមធម្មជាតិនៃទ្រព្យ។ មានន័យថា សមាសភាពទ្រព្យសម្បត្តិសាធារណៈមាន២ គឺៈទី១ ទ្រព្យសម្បត្តិដែលកើតឡើងពីធម្មជាតិឬដោយឯកឯងជាអាទិ៍ បឹង ស្ទឹង ទន្លេ ច្រាំងទន្លេ សមុទ្រ ត្រើយសមុទ្រ ភ្នំ កោះ និងទី២ គឺជាទ្រព្យសម្បត្តិទាំងឡាយណាដែលកើតឡើងពីនិមិត្តកម្មឬដោយការកែច្នៃដោយស្នាដៃមនុស្សជាអាទិ៍ សួនច្បារ ឧទ្យាន ផ្លូវថ្នល់ ផ្លូវរទេះភ្លើង សំណង់អគារ...សម្រាប់ប្រើប្រាស់ជាសាធារណៈឬបម្រើសេវាសាធារណៈ។ តាមគោលការណ៍នៃការបែងចែកសមាសភាពទ្រព្យទៅតាមធម្មជាតិនៃទ្រព្យសម្បត្តិនេះ មាត្រា ១៥ នៃនីតិភូមិបាលឆ្នាំ២០០១ ក៏បានបញ្ញត្តិដូចគ្នានោះផងដែរ។

(២)-របបគតិយុត្តគ្រប់គ្រងទ្រព្យសម្បត្តិសាធារណៈ៖ តាមគោលការណ៍ទ្រព្យនេះ ទ្រព្យសម្បត្តិសាធារណៈដាច់ខាតមិនអាចលក់បានទេ។ ដោយហេតុថា ទ្រព្យសម្បត្តិនេះជាមធ្យោបាយសម្រាប់ធានាចំណូលថវិការដ្ឋតាមរយៈការប្រមូលពន្ធអំពីអ្នកដែលប្រើប្រាស់ទ្រព្យនោះ។ ប៉ុន្តែបច្ចុប្បន្ននេះ គោលការណ៍ខាងលើត្រូវបានលើកលែងដោយអ្នកនីតិមួយរូបឈ្មោះ **M.Waline** ជនជាតិបារាំងគាត់បានលើកឡើងថា ទ្រព្យសម្បត្តិសាធារណៈក៏អាចលក់បានដែរ ប៉ុន្តែត្រូវអនុវត្តតាម***វិធីអនុបយោគ*** និងកំណត់***លក្ខខណ្ឌឱ្យបានតឹងរឹង*** បំផុត។ បានសេចក្តីថា ទ្រព្យសម្បត្តិសាធារណៈក៏អាចលក់បានដែរ ប៉ុន្តែត្រូវធ្វើអនុបយោគទ្រព្យសម្បត្តិនេះមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋជាមុននៅពេលដែលទ្រព្យសម្បត្តិសាធារណៈនេះឈប់បម្រើវិស័យសាធារណៈ។ ទ្រព្យសម្បត្តិសាធារណៈ តាមគោលការណ៍

គ្មានការកំណត់អាជ្ញាយុកាលទេ ដោយហេតុថាទ្រព្យនេះទុក ដើម្បីជានាមិនឱ្យមានការផុតរលត់ដែលនាំឱ្យបង្កើតបានជាកម្មសិទ្ធិឯកជន។ តាមគោលការណ៍នេះ មាត្រា១៦ នៃនីតិភូមិបាលឆ្នាំ២០០១ ក៏មានបញ្ញត្តិយ៉ាងដូច្នេះដែរ។

(៣)-ការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈ៖ ទ្រព្យសម្បត្តិសាធារណៈ ត្រូវប្រើប្រាស់ឱ្យចំគោលដៅនៃទ្រព្យ ដោយមិនត្រូវធ្វើឱ្យប៉ះពាល់ឬខូចខាតដល់ទ្រព្យ ឬបង្កឧបសគ្គដល់ការថែរក្សាទ្រព្យសម្បត្តិនេះទេ ការប្រើប្រាស់ត្រូវអនុវត្តជាលក្ខណៈសាធារណៈដូចជា ផ្លូវថ្នល់ សួនច្បារ មន្ទីរពេទ្យ សាលារៀន សារមន្ទីរ...។ល។ ដូចនេះ អ្នកប្រើប្រាស់ទ្រព្យត្រូវថែទាំនិងមិនបង្កឱ្យខូចខាតទ្រព្យនេះទេ។ ប៉ុន្តែមានទ្រព្យសម្បត្តិសាធារណៈមួយចំនួនមិនត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈទេដូចជា ទ្រព្យសម្បត្តិនៅក្នុងវិស័យយោធាឬទ្រព្យសម្បត្តិដែលពាក់ព័ន្ធនឹងការការពារសុវត្ថិភាពសាធារណជន។ ដោយឡែក ចំពោះអ្នកដែលប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈដោយផ្ទាល់តាមគោលការណ៍គឺ ពុំចាំបាច់មានកិច្ចសន្យាឬលិខិតអនុញ្ញាតអំពីរដ្ឋឡើយ ហើយក៏មិនគិតថ្លៃឈ្នួលលើការប្រើប្រាស់ទ្រព្យនោះដែរ។ ម្យ៉ាងទៀត អ្នកប្រើប្រាស់ទ្រព្យដោយផ្ទាល់គឺ មានសេរីភាពនិងសមភាពក្នុងការប្រើប្រាស់ទ្រព្យនោះ ប៉ុន្តែក៏មិនត្រូវរំខានដល់អ្នកប្រើប្រាស់ដទៃទៀតដែរ។ ក្រៅពីការប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈដោយផ្ទាល់ ទ្រព្យសម្បត្តិសាធារណៈក៏ត្រូវបានដាក់ឱ្យប្រើប្រាស់ជាសាធារណៈឬរួមផងដែរដូចជា សំណង់ដែលរដ្ឋបានសាងសង់ទុកសម្រាប់ជួល ស្ថានីយប្រេងឥន្ធនៈ ចំណតរថយន្ត ផ្សារលក់ដូរ កំពង់ចម្លង...។ល។ និង។ល។ ប៉ុន្តែតម្រូវឱ្យអ្នកប្រើប្រាស់ទ្រព្យសម្បត្តិទាំងនោះមានកាតព្វកិច្ចបង់ពន្ធជូនរដ្ឋ លិខិតអនុញ្ញាត និងកិច្ចសន្យាឬសៀវភៅបន្ទុកជាមួយរដ្ឋ។ ប៉ុន្តែការអនុញ្ញាតឱ្យប្រើប្រាស់ទ្រព្យវិញ គឺមានលក្ខណៈបណ្តោះអាសន្ន មិនទៀង និងអាចដកហូតទ្រព្យនេះវិញបានគ្រប់ពេលវេលា ក្នុងករណីអ្នកប្រើប្រាស់មិនគោរពត្រឹមត្រូវតាមលក្ខខណ្ឌទាំងឡាយដែលរដ្ឋបានកំណត់ឬបានរំខានដល់ការប្រើប្រាស់ដ៏ទៃទៀត។ ផ្អែកតាមគោលការណ៍នេះ ទើបរដ្ឋមានអំណាចឆន្ទានុសិទ្ធិក្នុងការអនុញ្ញាតយល់ព្រមឬបដិសេធមិនឱ្យប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈឬសិទ្ធិកែប្រែ ឬលុបកិច្ចសន្យាដោយឯកតោភាគីបាន ក្នុងករណីដែលអ្នកប្រើប្រាស់ទ្រព្យនោះ ពុំបានគោរពត្រឹមត្រូវតាមលក្ខខណ្ឌក្នុងកិច្ចសន្យា។ ផ្ទុយទៅវិញ អ្នកប្រើប្រាស់ទ្រព្យសម្បត្តិសាធារណៈក៏មានសិទ្ធិទាមទារសំណងការខូចខាតរបស់ខ្លួនផងដែរ ប្រសិនបើការកែប្រែឬលុបកិច្ចសន្យានោះពុំមែនជាកំហុសរបស់ខ្លួន (នីតិរដ្ឋបាលនៃទ្រព្យសម្បត្តិសាធារណៈរបស់សាស្ត្រាចារ្យបណ្ឌិត **ស៊ី សុជាតិ** ឆ្នាំ២០០៧)។ ចំពោះគោលការណ៍ខាងលើ មាត្រា១៦ នៃនីតិភូមិបាលឆ្នាំ២០០១ ក៏បានបញ្ញត្តិដូចគ្នានេះដែរ។

ដូចនេះ តាមសម្មតិកម្មគោលការណ៍នីតិរដ្ឋបាលនៃទ្រព្យសម្បត្តិសាធារណៈនិងតាមបញ្ញត្តិនៃនីតិភូមិបាលឆ្នាំ២០០១ ដែននេសាទគឺជា **ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ** យ៉ាងពិតប្រាកដ។

**ឃ- អាជ្ញាធរមានសមត្ថកិច្ចគ្រប់គ្រងដែននេសាទ**

មាត្រា៩ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ញត្តិថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ ហើយមានសិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ដែននេសាទដល់រូបវន្តបុគ្គល ឬនីតិបុគ្គលដើម្បីធ្វើ

អាជីវកម្មនេសាទប្រមូលផលធនធានជលផល ស្រាវជ្រាវបច្ចេកទេសវិទ្យាសាស្ត្រជលផល ឬតម្រូវការចាំបាច់ផ្សេងទៀត។ ប៉ុន្តែបើការប្រើប្រាស់ដែននេសាទនោះ ដើម្បីគោលបំណងក្រៅពីវិស័យជលផលវិញ ការសម្រេចគឺជាសិទ្ធិរបស់រាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ចំពោះអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋ មាត្រា២ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥ បានកំណត់ថា អាជ្ញាធរកាន់កាប់ដីរដ្ឋគឺ សំដៅដល់ក្រសួងឬស្ថាប័ន ឬអាជ្ញាធរដែនដីដែលរដ្ឋបានប្រគល់ដីរដ្ឋណាមួយជាក់លាក់សម្រាប់ធ្វើការគ្រប់គ្រង ថែរក្សា ការពារ និងប្រើប្រាស់បម្រើឱ្យស្ថាប័ននោះ។ មាត្រា២ នៃអនុក្រឹត្យស្តីពីវិធាននិងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈឆ្នាំ២០០៦ វិញបានកំណត់ដែរថា រាជរដ្ឋាភិបាល គឺជាអ្នកគ្រប់គ្រងរាល់ទ្រព្យសម្បត្តិរបស់រដ្ឋដែលស្ថិតនៅក្រោមការកាន់កាប់ ការប្រើប្រាស់ ការថែរក្សា និងការធ្វើអាជីវកម្មរបស់ក្រសួង ស្ថាប័ន រាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់ ឬរបស់នីតិបុគ្គលសាធារណៈ។ តំណាងឱ្យរាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋ គឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ បានសេចក្តីថា ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអាជ្ញាធរគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋនិងជាសេនាធិការឱ្យរាជរដ្ឋាភិបាលលើការលក់ ដូរ ឬជួលទ្រព្យសម្បត្តិរបស់រដ្ឋជូនរាជរដ្ឋា-ភិបាល។ ចំណែកអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរបស់រដ្ឋវិញ មានសមត្ថកិច្ចត្រឹមតែប្រើប្រាស់ ថែរក្សា និងស្នើសុំលក់ ដូរ ឬជួលទ្រព្យសម្បត្តិនោះតែប៉ុណ្ណោះ។ ហេតុនេះហើយ ទើបរាល់ការលក់ ដូរ ឬជួលទ្រព្យសម្បត្តិរបស់រដ្ឋម្តងៗ គេតែងសង្កេតឃើញមានតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុចូលរួមជានិច្ច។ ជាក់ស្តែង ដូចជាការដេញថ្លៃឈ្នួលឡូត៍នេសាទ ភាស៊ីផ្សារ កំពង់ចម្លង ស្ថានីយប្រេងឥន្ធនៈ។ល។និង។ល។

## ជំពូកទី២: នីតិវិធីផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទ

### ១- លក្ខណៈវិនិច្ឆ័យលើសំណើសម្បទានដីសេដ្ឋកិច្ច

ការវាយតម្លៃលើសំណើសម្បទានដីសេដ្ឋកិច្ច ត្រូវផ្អែកទៅលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

-ការបង្កើនផលិតផលកសិកម្មនិងកសិ-ឧស្សាហកម្មដោយប្រើប្រាស់បច្ចេកទេសទំនើប

-ការបង្កើតឱ្យមានការងារធ្វើកាន់តែច្រើន

-ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

-ការការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

-ការចៀសវាងឬការកាត់បន្ថយឱ្យនៅតិចបំផុតនូវហេតុប៉ះពាល់ជាអវិជ្ជមាន

-ការផ្សារភ្ជាប់និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ចនិងសម្បទានសង្គមកិច្ច ប្រសិនបើមាន និង

-ការកែច្នៃវត្ថុធាតុដើម ជាកសិផលដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាសម្បទាន (មាត្រា៥ នៃអនុក្រឹត្យគ្រប់-គ្រងដីរដ្ឋ)។

### ២- នីតិវិធី

### ក- ការផ្តួចផ្តើមសម្បទានដីសេដ្ឋកិច្ច

ការផ្តួចផ្តើមសម្បទានដីសេដ្ឋកិច្ចតាមបញ្ញត្តិមាត្រា៦ នៃអនុក្រឹត្យគ្រប់គ្រងដីរដ្ឋមាន២ គឺ៖

១-សំណើមានការអំពាវនាវដោយអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាមួយអ្នកលើកគម្រោង ដើម្បីអំពាវនាវវិនិយោគិនដាក់សំណើ។

២-សំណើគ្មានការអំពាវនាវដោយរដ្ឋជាអ្នកលើកគម្រោងស្នើសុំវិនិយោគិនធ្វើសម្បទានដីសេដ្ឋកិច្ច។

### ក-១- ការផ្តួចផ្តើមសម្បទានដីសេដ្ឋកិច្ចតាមរយៈការអំពាវនាវឱ្យដាក់សំណើ

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ជាអ្នកផ្តួចផ្តើមលើកគម្រោងសម្បទានដីសេដ្ឋកិច្ចតាមជំហានដូចតទៅ៖

១-រៀបចំឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ចតាមទម្រង់ដែលត្រូវបង្កើតឡើងដោយលេខាធិការដ្ឋានបច្ចេកទេស ហើយត្រូវបញ្ចូលព័ត៌មានមួយចំនួនដូចខាងក្រោម៖

-ការពិពណ៌នាអំពីដីដែលស្នើឡើងដូចជា ទីតាំង ទំហំ ប្រភេទ លេខសម្គាល់ក្បាលដីដែលចុះក្នុងបញ្ជីសៀវភៅគោលបញ្ជីដីធ្លី និងព័ត៌មានទូទៅអំពីតំបន់ដែលដីនោះស្ថិតនៅ

-ផែនការទូទៅអំពីការប្រើប្រាស់និងការអភិវឌ្ឍសម្រាប់គម្រោងសម្បទាន

-សកម្មភាពចាំបាច់ផ្សេងៗ ដែលតម្រូវឱ្យសម្បទានិកធ្វើមុនពេលចាប់ផ្តើមសកម្មភាពលើសម្បទានដីសេដ្ឋកិច្ចនោះ ប្រសិនបើមាន

-សកម្មភាពចាំបាច់ផ្សេងៗ ដែលតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាឬក្រសួង ស្ថាប័នណាមួយធ្វើមុនពេលចាប់ផ្តើមអនុវត្តសកម្មភាពសម្បទានដីសេដ្ឋកិច្ច ប្រសិនបើមាននិង

-ការធានារបស់រដ្ឋឬកាតព្វកិច្ចរបស់រដ្ឋ ប្រសិនបើតម្រូវឱ្យមានសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច។

២-បញ្ជូនឯកសារដំបូងទៅលេខាធិការដ្ឋានបច្ចេកទេស ដើម្បីធ្វើការពិនិត្យសិក្សានិងផ្តល់អនុសាសន៍បឋមដោយផ្អែកលើគោលបំណងនិងការវាយតម្លៃសំណើនៃសម្បទានដីសេដ្ឋកិច្ច។

៣-ពិគ្រោះយោបល់ជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តនិងជាមួយស្ថាប័នដាក់បញ្ញត្តិលើគម្រោងសម្បទានដីសេដ្ឋកិច្ច។

៤-រៀបចំឱ្យមានការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាននិងសង្គមសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច។

ចំពោះបញ្ហានេះ ការអនុវត្តជាក់ស្តែងកន្លងមកមុននឹងចាប់ផ្តើមធ្វើសម្បទានដីសេដ្ឋកិច្ចសម្បទានិកតែងតែធ្វើការទំនាក់ទំនងជាមួយរដ្ឋាភិបាលសុំការគាំទ្រជាមុន បន្ទាប់មករាជរដ្ឋាភិបាលក៏បានដាក់ចេញនូវសេចក្តីជូនដំណឹង (សជណ) របស់គណៈរដ្ឋមន្ត្រីមួយជម្រាបជូនក្រសួង ស្ថាប័ន អាជ្ញាធរដែនដីពាក់ព័ន្ធ វិនិយោគិន និងប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋានធ្វើការសិក្សាវាយតម្លៃអំពីផលប៉ះពាល់បរិស្ថាននិងសង្គមនូវទីតាំងដែលត្រូវធ្វើសម្បទានដីសេដ្ឋ-កិច្ច រួចហើយរាយការណ៍ជូនរាជរដ្ឋាភិបាលវិញ ដើម្បីសុំការសម្រេចផ្តល់សម្បទានដីសេដ្ឋកិច្ចជូនវិនិយោគិន។

៥-ប្រសិនបើការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាននិងសង្គមបានបង្ហាញនូវហេតុប៉ះពាល់អវិជ្ជមានក្នុងកម្រិតមធ្យមឬខ្ពស់ ក្រុមការងារដែលមានសមាសភាពក្នុងសេចក្តីជូនដំណឹង (សជណ) ចំណុច៤ ខាងលើ ត្រូវរៀបចំឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គមបន្ថែមទៀតឱ្យបានពេញលេញ។

៦-ឯកសារដែលបានរៀបចំពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ចដែលមានបញ្ចូលអនុសាសន៍ទាំងអស់និងរបាយការណ៍នានាដែលជាលទ្ធផលនៃជំហានដូចបានរៀបរាប់ខាងលើ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការរៀបចំឯកសារស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើដែលមានការអំពាវនាវ (មាត្រា៣ មាត្រា៥ មាត្រា៧ និងមាត្រា៨ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

នៅពេលទទួលបានឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ចអំពីអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យារួច លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំឯកសារដោយមានការអំពាវនាវឱ្យដាក់សំណើសុំសម្បទានដីសេដ្ឋកិច្ចដូចខាងក្រោម៖

-សេចក្តីជូនដំណឹង

-ឯកសារស្តីពីលក្ខខណ្ឌនិង

-ពាក្យស្នើសុំ។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនូវសេចក្តីជូនដំណឹងឱ្យដាក់សំណើនិងបញ្ជូនសេចក្តីជូនដំណឹងនេះទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។

សេចក្តីជូនដំណឹងនេះ ត្រូវបញ្ជាក់ពីរបៀប ទីកន្លែងនិងរយៈពេលសមស្របក្នុងការដាក់សំណើដោយកំណត់នូវកាលបរិច្ឆេទទទួលនិងឈប់ទទួលពាក្យ។ ការដាក់សំណើត្រូវមានរយៈពេលយ៉ាងតិច៦០ (ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃ ជូនដំណឹង (មាត្រា១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

ពាក្យស្នើសុំតាមការដាក់សំណើដែលមានការអំពាវនាវ ផ្អែកតាមមាត្រា៩ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចត្រូវបញ្ចូលខ្លឹមសារមួយចំនួនដូចខាងក្រោម៖

-សេចក្តីពណ៌នាអំពីគម្រោងសម្បទានដីសេដ្ឋកិច្ចនិងឯកសារគាំទ្រដែលតម្រូវឱ្យដាក់ភ្ជាប់ជាមួយសំណើ

-លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងពាណិជ្ជកម្មនៃសំណើ និង

-លក្ខខណ្ឌចាំបាច់មួយចំនួនដែលមិនអនុញ្ញាតឱ្យចរចា (មាត្រា១១ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

ពាក្យស្នើសុំតាមការដាក់សំណើដែលមានការអំពាវនាវ ក៏ត្រូវមានភ្ជាប់នូវព័ត៌មានមួយចំនួនផងដែរជាអាទិ៍៖

-ផែនការអាជីវកម្មដែលលំអិតអំពីផែនការប្រើប្រាស់ដី ផែនការវិនិយោគ ផែនការចំណូល ចំណាយសម្រាប់ការអភិវឌ្ឍដីនិងប្រភពដើមទុនសម្រាប់គាំទ្រដល់គម្រោងសម្បទាន

-ការពិណ៌នាអំពីសេចក្តីត្រូវការកម្លាំងពលកម្មនិងប្រភពផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់គម្រោងសម្បទាន

-ព័ត៌មានអំពីបច្ចេកវិទ្យា ឧបករណ៍ គ្រឿងចក្រ ជី ថ្នាំសម្លាប់សត្វល្អិត ប្រភេទដំណាំអាទិភាពដែលគ្រោងនឹងប្រើប្រាស់

-ការបង្ហាញអំពីហេតុប៉ះពាល់បរិស្ថាននិងសង្គមនៃសកម្មភាពគម្រោងវិនិយោគរបស់ខ្លួន ព្រមទាំងវិធានការទប់ស្កាត់ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន

-ការពណ៌នាអំពីការផ្សារភ្ជាប់និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ចនិងសម្បទានដីសង្គមកិច្ចប្រសិនបើមាន

-ការពណ៌នាអំពីការផ្សារភ្ជាប់ទៅនឹងការកែច្នៃវត្ថុធាតុដើមដែលជាកសិផលក្នុងស្រុក ប្រសិនបើមាន

-ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើជូនរដ្ឋ

-ការបង្ហាញព័ត៌មានអំពីការកាន់កាប់ដីសម្បទាសេដ្ឋកិច្ចដោយម្ចាស់សំណើប្រសិនបើមាន ត្រូវតែស្របនឹងមាត្រា៥៩ នៃនីតិភូមិបាលឆ្នាំ២០០១។

មាត្រា៥៩ នៃនីតិភូមិបាលឆ្នាំ២០០១ បានបញ្ញត្តិថាៈ *"សម្បទានដី អាចមានទំហំច្រើនបំផុតត្រឹមតែ១០.០០០*

*(មួយម៉ឺន)ហិកតា។ សម្បទានដីដែលសម្រេចហើយ ហើយមានទំហំលើសពីទំហំកំណត់ខាងលើ ជាកម្មវត្ថុនៃការកាត់បន្ថយ។ ប៉ុន្តែប្រសិនបើការកាត់បន្ថយនេះមានឥទ្ធិពលធ្វើឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការ សម្បទានិកអាចនឹងទទួលបានការលើកលែងជាពិសេស។ នីតិវិធីនៃការកាត់បន្ថយនិងការលើកលែងជាពិសេស ត្រូវកំណត់ដោយអនុក្រឹត្យ។"*

*ត្រូវបានហាមឃាត់ការចេញលិខិតសម្បទានដីច្រើនកន្លែងឱ្យបុគ្គលតែម្នាក់ឬឱ្យនីតិបុគ្គលច្រើន តែគ្រប់គ្រងដោយរូបវន្តបុគ្គលឬនីតិបុគ្គលដដែលៗ ដែលមានទំហំសរុបធំជាងទំហំដែលបានកំណត់នៅវាក្យខណ្ឌខាងលើ។"*

-កិច្ចធានាណាមួយដែលអ្នកដាក់សំណើចង់បានពីរដ្ឋ ប្រសិនបើមាន (មាត្រា១២ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវរៀបចំការប្រជុំជាសាធារណៈ ដើម្បីបំភ្លឺអំពីចំណុចនានានៃឯកសារអំពាវនាវឱ្យដាក់សំណើយ៉ាងតិច៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទបិទការទទួលសំណើនិងត្រូវកត់ត្រាទុកជាឯកសារសាធារណៈនូវការបំភ្លឺដែលបានធ្វើឡើង(មាត្រា១៣ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃនិងចាត់ថ្នាក់សំណើមានការអំពាវនាវត្រូវមានបញ្ចូលចំណុចដូចខាងក្រោម៖

-កម្រិតបច្ចេកទេសនៃការប្រើប្រាស់និងការវិវឌ្ឍដី រួមទាំងភាពសមស្របរបស់ដី

-ការគោរពតាមស្តង់ដារបរិស្ថានជាតិនិងវិធានការសមស្របសម្រាប់ទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាននិងសង្គម

-លទ្ធភាពដំណើរការប្រតិបត្តិការនៃសំណើដោយផ្អែកជាអាទិ៍ លើផែនការផ្គត់ផ្គង់និងតម្រូវការកម្លាំងពលកម្ម ប្រភពហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រទីផ្សារនៃផែនការអាជីវកម្ម

-លទ្ធភាពបង្កើតការងារធ្វើនិងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ

-ការកែច្នៃវត្ថុធាតុដើមឬកសិផលក្នុងស្រុកដែលត្រូវកំណត់ក្នុងកិច្ចសន្យា

-លទ្ធភាពផ្សារភ្ជាប់និងគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ចនិងសម្បទានសង្គមកិច្ច

-ចំនួនទឹកប្រាក់និងរបៀបបង់ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើឡើង។

លក្ខណៈវិនិច្ឆ័យសម្រាប់ការវាយតម្លៃនិងការចាត់ថ្នាក់សំណើ មិនអាចធ្វើការកែប្រែបានឡើយ ក្រោយពីចុះផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើដែលមានការអំពាវនាវ អនុលោមតាមមាត្រា១០ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវរៀបចំនិងផ្សព្វផ្សាយអំពីការដាក់ពិន្ទុសម្រាប់ការចាត់ថ្នាក់សំណើនីមួយៗតាមលំដាប់ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យខាងលើ (មាត្រា១៤ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

សំណើត្រូវដាក់នៅលេខាធិការដ្ឋានបច្ចេកទេសក្នុងស្រោមសំបុត្របិទជិតនិងចុះហត្ថលេខា ឬបោះត្រារបស់ម្ចាស់សំណើលើស្នាមបិទមុខសំបុត្រ។ សំណើដែលបានទទួលក្រោយកាលបរិច្ឆេទបិទការទទួលសំណើ ត្រូវបង្វិលឱ្យម្ចាស់សំណើវិញដោយមិនត្រូវបើកស្រោមសំបុត្រឡើយ។ សំណើទាំងអស់ឬសំណើតែមួយ ដែលបានទទួលត្រូវបើកជាសាធារណៈតាមកាលបរិច្ឆេទដែលបានកំណត់ក្នុងសេចក្ដីអញ្ជើញឱ្យដាក់សំណើមានសិទ្ធិចូលរួមមើលការបើកសំណើ។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវកំណត់សំណើណាដែលមានលក្ខណៈឆ្លើយតប ហើយពិនិត្យនិងលើកអនុសាសន៍លើសំណើនោះជូនទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាដោយផ្អែកលើលក្ខណៈវិនិច្ឆ័យដែលចែងក្នុងមាត្រា១៤ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ចនិងតាមនីតិវិធីដែលមានក្នុងឯកសារស្ដីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើ (មាត្រា១៥ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

បន្ទាប់ពីការពិចារណាលើអនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធ្វើការវាយតម្លៃនិងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើដែលមានលក្ខណៈឆ្លើយតបទាំងអស់ និងរៀបចំរបាយការណ៍វាយតម្លៃសំណើដែលមានលក្ខណៈឆ្លើយតប ហើយផ្ដល់របាយការណ៍វាយតម្លៃនោះមួយច្បាប់ឱ្យម្ចាស់សំណើវិញ (មាត្រា១៦ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវបានអនុញ្ញាតឱ្យធ្វើការចរចាលើលក្ខខណ្ឌចាំបាច់មួយចំនួនដែលបានកំណត់ជាមុនថា មិនអនុញ្ញាតឱ្យចរចានៅក្នុងឯកសារអំពាវនាវឱ្យដាក់សំណើនោះឡើយ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវអញ្ជើញម្ចាស់សំណើដែលជាប់លំដាប់ថ្នាក់ខ្ពស់ជាងគេមកធ្វើការចរចាកិច្ចសន្យាសម្បទាន។ ប្រសិនបើការចរចាមិនអាចឈានដល់ការសម្រេចបានកិច្ចសន្យាសម្បទានដោយមកពីអាជ្ញាធរមិនអាចទទួលយកលក្ខខណ្ឌដែលស្នើឡើងចុងក្រោយដោយម្ចាស់សំណើ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវបញ្ឈប់ការចរចាជាមួយម្ចាស់សំណើ ហើយត្រូវអញ្ជើញអ្នកដាក់សំណើដែលជាប់លំដាប់ថ្នាក់បន្ទាប់ មកធ្វើការចរចាកិច្ចសន្យាជាបន្តបន្ទាប់។

ប្រសិនបើការចរចាឈានដល់ការសម្រេចបាននូវសេចក្ដីព្រាងកិច្ចសន្យាសម្បទាន អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវឱ្យម្ចាស់សំណើបំពេញលក្ខខណ្ឌដូចខាងក្រោម៖

មុនចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អ្នកដាក់សំណើត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្ដីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា១៧ និងមាត្រា២៣ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

ក្នុងករណីដែលមានសំណើតែមួយឬពីរ លេខាធិការដ្ឋានបច្ចេកទេសក៏ត្រូវអនុវត្តតាមនីតិវិធីដែលមានចែងក្នុងមាត្រាខាងលើដែរ។

**ក-២- ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចតាមរយៈសំណើគ្មានការអំពាវនាវ**

វិធីសាស្ត្រជាអាទិភាពសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺជាវិធីសាស្ត្រដែលរដ្ឋអំពាវនាវឱ្យដាក់សំណើក្នុងលក្ខណៈប្រកួតប្រជែង ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទាន អាចពិចារណាលើសំណើសម្បទានដីសេដ្ឋកិច្ចដែលមិនមានការអំពាវនាវណាមួយបាន ក្នុងករណីម្ចាស់សំណើសន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខណៈពិសេស ដើម្បីសម្រេចនូវគោលបំណងនៃសម្បទានដីសេដ្ឋកិច្ចមានជាអាទិ៍៖

-ការនាំមកនូវបច្ចេកវិទ្យាថ្មី

-ការផ្សារភ្ជាប់ជាពិសេសរវាងសម្បទានដីសេដ្ឋកិច្ចទៅនឹងសម្បទានដីសង្គមកិច្ច

-លទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃឬទីផ្សារនាំចេញ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវទទួលយកមកពិចារណានូវសំណើសម្បទានដីសេដ្ឋកិច្ចមិនមានការអំពាវនាវទេ ប្រសិនបើសំណើនោះទាក់ទងទៅនឹងដីដែលជាកម្មវត្ថុនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវ-នាវដែលបានផ្សព្វផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើរួច (មាត្រា១៨ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវរៀបចំពាក្យសុំសម្រាប់លើកសំណើមិនមានការអំពាវនាវដោយបញ្ចូលសេចក្តីពណ៌នាសង្ខេបអំពីសាវតារផ្នែកអាជីវកម្មនិងហិរញ្ញវត្ថុរបស់ម្ចាស់សំណើគោលគំនិតស្តីពីការវិនិយោគដែលស្នើឡើង ព្រមទាំងព័ត៌មានទាក់ទងទៅនឹងទំហំដីនិងទីតាំងដី។

ម្ចាស់សំណើ អាចដាក់ពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬនៅអនុគណៈកម្មការវិនិយោគរាជធានី ខេត្តឬនៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា។ ប្រសិនបើពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវ ត្រូវបានដាក់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាឬនៅអនុគណៈកម្មការវិនិយោគរាជធានី ខេត្ត ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មការវិនិយោគរាជធានី ខេត្ត ត្រូវបញ្ជូនសំណើនោះទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាក្នុងរយៈពេល០៧ (ប្រាំពីរ) ថ្ងៃ គិតពីថ្ងៃបានទទួលពាក្យសុំ។

ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សម្រេចធ្វើការពិចារណាសំណើមិនមានការអំពាវនាវ អាជ្ញាធរត្រូវធ្វើការពិគ្រោះយោបល់ជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត និងជាមួយស្ថាប័នដាក់បញ្ញត្តិលើគម្រោងសម្បទានដីសេដ្ឋកិច្ច (មាត្រា៧ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។ បន្ទាប់មក អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវរៀបចំបំពេញលក្ខណៈវិនិច្ឆ័យសម្រាប់ការជ្រើសរើសដីសម្បទានដូចមានចែងក្នុងលក្ខខណ្ឌទូទៅសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច ហើយស្នើឱ្យម្ចាស់សំណើផ្តល់ជូននូវឯកសារលម្អិតនៃសំណើ (មាត្រា៤ និងមាត្រា១៩ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

ឯកសារលម្អិតនៃសំណើមិនមានការអំពាវនាវ ត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម៖

-ព័ត៌មានដូចបានអធិប្បាយរួចក្នុងបញ្ញត្តិនៃមាត្រា១២ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចនិង

-របាយការណ៍នៃការសិក្សាវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាននិងសង្គម។ ប្រសិនបើការសិក្សាវាយតម្លៃដំបូងបង្ហាញថា អាចមានហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យមឬខ្ពស់ សំណើនោះត្រូវបញ្ចូលរបាយការណ៍នៃការវាយតម្លៃពេញលេញអំពីហេតុប៉ះពាល់បរិស្ថាននិងសង្គម (មាត្រា២០ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

អនុលោមតាមបញ្ញត្តិនៃមាត្រា៣១ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចដែលបានកំណត់សមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេសមានដូចខាងក្រោម៖

| | |
|---|---|
| -តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ជាប្រធាន |
| -តំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ជាសមាជិក |
| -តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ជាសមាជិក |
| -តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ជាសមាជិក |
| -តំណាងក្រសួងមហាផ្ទៃ | ជាសមាជិក |
| -តំណាងក្រសួងបរិស្ថាន | ជាសមាជិក |
| -តំណាងក្រសួងពាណិជ្ជកម្ម | ជាសមាជិក |
| -សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | ជាសមាជិក |

ប្រធាននិងសមាជិកនៃលេខាធិការដ្ឋានបច្ចេកទេស ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។ ចំណែកមន្ត្រីជំនួយការរបស់លេខាធិការដ្ឋានបច្ចេកទេស ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមសំណើរបស់លេខាធិការដ្ឋានបច្ចេកទេស។ លេខាធិការដ្ឋានបច្ចេកទេស មានទីតាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ បច្ចុប្បន្នលេខាធិការដ្ឋានបច្ចេកទេសខាងលើ ត្រូវបានបង្កើតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៦ ហើយមានទីតាំងបំពេញការងារស្ថិតនៅទីស្តីការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

លេខាធិការដ្ឋានបច្ចេកទេសមានភារកិច្ចដូចខាងក្រោម៖

-រៀបចំគម្រោងសម្បទានដីសេដ្ឋកិច្ច

-រៀបចំឯកសារអំពាវនាវឱ្យដាក់សំណើសម្បទានដីសេដ្ឋកិច្ច

-ផ្តល់អនុសាសន៍ចំពោះសំណើសម្បទានដីសេដ្ឋកិច្ចទាំងអស់

-តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-ផ្តល់អនុសាសន៍អំពីការត្រួតពិនិត្យឡើងវិញនូវសម្បទានដែលមានស្រាប់និង

-បំពេញភារកិច្ចផ្សេងៗ ទៀតស្របតាមបញ្ញត្តិនៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច (មាត្រា៣២ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

ថវិកាសម្រាប់ប្រតិបត្តិការរបស់លេខាធិការដ្ឋានបច្ចេកទេស ត្រូវស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាននិងថវិការបស់លេខាធិការដ្ឋានបច្ចេកទេសបានមកពីថវិកាជាតិនិងហិរញ្ញប្បទានដែលបានមកពីប្រភពក្នុងស្រុក ឬក្រៅស្រុក ឬពីអ្នកផ្ដល់ជំនួយអន្តរជាតិ (មាត្រា៤៣ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

ចំពោះអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាដែលបានទទួលសំណើមិនមានការអំពាវនាវ ត្រូវអនុវត្តតាមបែបបទដូចតទៅ៖

១-អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវបញ្ជូនឯកសារលម្អិតនៃសំណើមិនមានការអំពាវនាវទៅលេខាធិការដ្ឋានបច្ចេកទេសឬទៅគណៈកម្មការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត ដើម្បីពិនិត្យនិងផ្ដល់អនុសាសន៍។

២-លេខាធិការដ្ឋានបច្ចេកទេសឬគណៈកម្មការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត ត្រូវផ្ដល់អនុសាសន៍ជូនអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាថាគួរ ឬមិនគួរធ្វើការចរចាកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចដូចបានលើកឡើងខាងលើតាមខ្លឹមសារនៃបញ្ញត្តិមាត្រា៣ ដល់មាត្រា៥ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច (មាត្រា២១ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

ការចរចាចុះកិច្ចសន្យាសម្រាប់គម្រោងសម្បទានមិនមានការអំពាវនាវ ត្រូវធ្វើក្នុងរយៈពេលយ៉ាងច្រើន២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃផ្ដើមការចរចា។ បើការចរចារមិនឈានដល់ការសម្រេចសេចក្ដីព្រាងកិច្ចសន្យាសម្បទានក្នុងរយៈពេលកំណត់នេះទេ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាអាចបញ្ឈប់ការពិចារណាលើសំណើនោះ។

មុនចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អ្នកដាក់សំណើត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្ដីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា (មាត្រា២២ និងមាត្រា២៣ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវរៀបចំស្តង់ដារនៃកិច្ចសន្យាសម្បទានដែលត្រូវប្រើសម្រាប់រាល់ពេលសម្បទានដីសេដ្ឋកិច្ចដោយត្រូវពិគ្រោះយោបល់និងកំណត់ប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (មាត្រា២៤ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

**ខ- ការគ្រប់គ្រងនិងការកែប្រែកិច្ចសន្យាសម្បទាន**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវទទួលខុសត្រូវក្នុងការធានាឱ្យមានការអនុវត្តកិច្ចសន្យាសម្បទានដោយបង្កើតយន្តការនិងនីតិវិធីសម្រាប់ការត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យាសម្បទាន និងរាយការណ៍ជាប្រចាំអំពីការគ្រប់គ្រងកិច្ចសន្យាសម្បទានទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ហើយផ្ដល់ព័ត៌មានដល់លេខាធិការដ្ឋានបច្ចេកទេសឬគណៈកម្មការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យាសម្បទានរបស់សម្បទានិកនិងទទួលព័ត៌មានពីសម្បទានិក និងពីក្រសួង ស្ថាប័នពាក់ព័ន្ធទាក់ទងទៅនឹងការអនុវត្តកិច្ចសន្យាសម្បទាន (មាត្រា២៥ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

មុននឹងកែប្រែកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងភាគីចុះកិច្ចសន្យាដោយអនុលោមតាមបញ្ញត្តិនិងច្បាប់ជាធរមាន។

ការពន្យារ ការព្យួរ ការបញ្ចប់កិច្ចសន្យាសម្បទាន ត្រូវកំណត់ក្នុងកិច្ចសន្យាសម្បទាន (មាត្រា២៦ និងមាត្រា ២៧ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

### គ- យន្តការរដ្ឋបាលនិងការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

យន្តការសម្បទានដីសេដ្ឋកិច្ចមានដូចខាងក្រោមៈ

-អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា

-លេខាធិការដ្ឋានបច្ចេកទេស

-គណៈកម្មការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត

-ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ

-ក្រុមប្រឹក្សាឃុំ សង្កាត់(មាត្រា២៨ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលមានទុនវិនិយោគចាប់ពី១០.០០០.០០០.០០០(ដប់ពាន់លាន)រៀលឡើងឬមានទំហំដីសម្បទានចាប់ពី១.០០០ (មួយពាន់)ហិកតាឡើងទៅ។

អភិបាលរាជធានី ខេត្តមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលមានទុនវិនិយោគក្រោម១០.០០០.០០០.០០០(ដប់ពាន់លាន)រៀលនិងមានទំហំដីសម្បទានក្រោម១.០០០ (មួយពាន់) ហិកតា(មាត្រា ២៩ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាមានតួនាទីនិងភារកិច្ចដូចខាងក្រោមៈ

-ផ្តួចផ្តើមនិងរៀបចំឯកសារគម្រោងសម្បទានដីសេដ្ឋកិច្ចសម្រាប់អំពាវនាវឱ្យមានការដាក់សំណើឬអាចពិចារណាសំណើគម្រោងសម្បទានដីសេដ្ឋកិច្ចដែលមិនមានការអំពាវនាវ

-វាយតម្លៃនិងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើ

-ចរចាលក្ខខណ្ឌសម្រាប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-ដាក់ឱ្យអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

-រាយការណ៍អំពីការគ្រប់គ្រងលើការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចជូនគណៈរដ្ឋមន្ត្រីជារៀងរាល់០៦ (ប្រាំមួយ) ខែម្តងនិងតាមការចាំបាច់។

-សម្របសម្រួល ប្រមូលព័ត៌មាននិងទិន្នន័យពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងការពារជាតិចំពោះដីក្នុងតំបន់អភិវឌ្ឍន៍យោធាលើលក្ខខណ្ឌដែលត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យាសម្បទាន

-ពិនិត្យយោបល់របស់លេខាធិការដ្ឋានបច្ចេកទេសអំពីសំណើកែប្រែកិច្ចសន្យាសម្បទានណាមួយនិង

-បំពេញភារកិច្ចផ្សេងៗ ទៀតស្របតាមបញ្ញត្តិនៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច (មាត្រា៣០ នៃ អនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

**គ-១- តួនាទី ភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត**

បញ្ញត្តិក្នុងមាត្រា២៥ នៃអនុក្រឹត្យស្តីពីគ្រប់គ្រងដីរដ្ឋបានកំណត់មុខងារនិងភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តដូចខាងក្រោម៖

-ដឹកនាំក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌក្នុងការធ្វើអត្តសញ្ញាណកម្ម និងការធ្វើផែនទីដីរដ្ឋ

-សម្របសម្រួលជាមួយក្រសួង ស្ថាប័ន អាជ្ញាធរដែនដីអំពីអាណត្តិកាន់កាប់និងឋានៈនៃដីរដ្ឋ

-ប្រមូលនិងចងក្រងឯកសារព័ត៌មានអំពីទីតាំង ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ

-ផ្តល់មតិយោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ឬក្រុមប្រឹក្សាគោលនយោបាយដីធ្លីអំពីអាណត្តិកាន់កាប់និងការធ្វើចំណាត់ថ្នាក់ដីរដ្ឋ ព្រមទាំងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

-ថែរក្សានិងធ្វើបន្តការប្រព័ន្ធទិន្នន័យនិងផែនទីដីរដ្ឋប្រចាំរាជធានី ខេត្ត

-សម្រេចនិងត្រួតពិនិត្យលើការរៀបចំផែនការសកម្មភាពប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ ដោយមានការចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លីនិងសហការតាមដានអនុវត្តទាំងនោះ

-សហការក្នុងការរៀបចំពិគ្រោះយោបល់ជាសាធារណៈលើគម្រោងសម្បទានដីធ្លី

-លើកគម្រោងថវិកាប្រចាំឆ្នាំនិង

-បំពេញភារកិច្ចផ្សេងៗទៀតស្របតាមបញ្ញត្តិច្បាប់ជាធរមាន។

តាមបញ្ញត្តិមាត្រា២៤ នៃអនុក្រឹត្យស្តីពីគ្រប់គ្រងដីរដ្ឋបានកំណត់សមាសភាពគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្តមានដូចខាងក្រោម៖

| | |
|---|---|
| -អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត | ជាប្រធាន |
| -ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត | ជាសមាជិកអចិន្ត្រៃយ៍ |
| -មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងរាជធានី ខេត្ត | ជាសមាជិក |
| -ស្នងការនគរបាលរាជធានី ខេត្ត | ជាសមាជិក |

-ប្រធានមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរកសិកម្មរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរបរិស្ថានរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរទេសចរណ៍រាជធានី ខេត្ត ជាសមាជិក

-ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ជាសមាជិក

-នាយខណ្ឌរដ្ឋបាលព្រៃឈើដែលជាប់ពាក់ព័ន្ធ ជាសមាជិក

-អគ្គលេខាធិការសាលារាជធានី ខេត្ត ជាសមាជិក

សមាសភាពដែលមានចែងខាងលើ ត្រូវអញ្ជើញចូលរួមតាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋរាជធានី ខេត្ត អាចអញ្ជើញតំណាងមន្ទីរពាក់ព័ន្ធផ្សេងទៀតចូលរួមជាសមាជិកតាមតម្រូវការនៃករណីនីមួយៗ។

**គ-២- តួនាទី ភារកិច្ចរបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌ**

បញ្ញត្តិក្នុងមាត្រា២៨ នៃអនុក្រឹត្យស្តីពីគ្រប់គ្រងដីរដ្ឋការកំណត់មុខងារនិងភារកិច្ចរបស់ក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌមានដូចខាងក្រោម៖

-ប្រមូលនិងចងក្រងឯកសារព័ត៌មាន ដើម្បីធ្វើអត្តសញ្ញាណកម្មនិងធ្វើផែនទីដីរដ្ឋ

-សម្របសម្រួលជាមួយស្ថាប័ន អាជ្ញាធរ ឬអ្នកកាន់កាប់ដីរដ្ឋអំពីអាណត្តិកាន់កាប់ដីរដ្ឋ

-ស្វែងរកការឯកភាពលើព្រំប្រទល់ប្រហាក់ប្រហែល ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ

-ធ្វើការបិទផ្សាយជាសាធារណៈនូវសំណៅព័ត៌មាននិងផែនទីដីរដ្ឋនៅតាមទីប្រជុំជន និងតាមឃុំ សង្កាត់ពាក់ព័ន្ធនិងទទួលមតិយោបល់ពីសាធារណៈតាមកាលបរិច្ឆេទ និងទីកន្លែងដែលបានកំណត់

-សង្ខេបមតិយោបល់សាធារណៈដែលបានទទួលនិងរៀបចំទិន្នន័យ និងឯកសារចាំបាច់ រួមទាំងផែនទីដីរដ្ឋ ដែលមានបញ្ជាក់ព័ត៌មានទាំងអស់ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត

-ចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីនិងផ្តល់មតិយោបល់ក្នុងការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ

-រៀបចំការពិគ្រោះយោបល់និងចូលរួមផ្តល់មតិយោបល់លើគម្រោងសម្បទានដីធ្លី ព្រមទាំងសហការតាមដានការអនុវត្តគម្រោងសម្បទានដីធ្លី និង

-បំពេញភារកិច្ចផ្សេងៗ ទៀតស្របតាមបញ្ញត្តិច្បាប់ជាធរមាន។

តាមបញ្ញត្តិមាត្រា២៧ នៃអនុក្រឹត្យស្តីពីគ្រប់គ្រងដីរដ្ឋការកំណត់សមាសភាពក្រុមការងារដីរដ្ឋថ្នាក់ស្រុក ខណ្ឌមានដូចខាងក្រោម៖

-អភិបាលនៃគណៈអភិបាលស្រុក ខណ្ឌ ជាប្រធាន

-ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ជាសមាជិកអចិន្ត្រៃយ៍

-ប្រធានការិយាល័យជំនាញថ្នាក់ស្រុក ខណ្ឌពាក់ព័ន្ធ ជាសមាជិក

-នាយផ្នែករដ្ឋបាលព្រៃឈើពាក់ព័ន្ធ ជាសមាជិក

-មេឃុំ ចៅសង្កាត់ក្នុងស្រុក ខណ្ឌ ជាសមាជិក

ប្រធាននិងសមាជិកនៃក្រុមការងារដីរដ្ឋស្រុកខណ្ឌ ត្រូវតែងតាំងដោយអភិបាលរាជធានី ខេត្ត។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវរៀបចំការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដីនិងតំណាងប្រជាពលរដ្ឋមូលដ្ឋាន ក្រោយពីទទួលបានឯកសារលម្អិតនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវឬឯកសារលម្អិតនៃសំណើមិនមានការអំពាវនាវដោយបញ្ជូនឯកសារនោះមួយច្បាប់ទៅឱ្យក្រុមប្រឹក្សាឃុំ សង្កាត់ដែលដីសម្បទានតាំងនៅ ដើម្បីពិនិត្យនិងផ្តល់យោបល់ក្នុងរយៈពេលយ៉ាងច្រើន២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលក្រុមប្រឹក្សាឃុំ សង្កាត់បានទទួលសំណៅឯកសារលម្អិតនៃគម្រោងសម្បទានមានការអំពាវនាវឬឯកសារលម្អិតនៃសំណើមិនមានការអំពាវនាវ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវពិចារណាលើមតិយោបល់របស់ក្រុមប្រឹក្សាឃុំ សង្កាត់ពាក់ព័ន្ធ។ ក្នុងករណីបដិសេធយោបល់ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវផ្តល់ហេតុផលច្បាស់លាស់ (មាត្រា៣៥ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

**ឃ- ការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់**

ការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលរដ្ឋាភិបាលអនុញ្ញាតមុនអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ចនេះចូលជាធរមាន ហើយដែលកិច្ចសន្យាសម្បទាននោះនៅមានសុពលភាព លេខាធិការដ្ឋានបច្ចេកទេសនិងក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលចុះកិច្ចសន្យាត្រូវអនុវត្តដូចខាងក្រោម៖

-លេខាធិការដ្ឋានបច្ចេកទេស ត្រូវបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ចក្នុងរយៈពេល៩០ (កៅសិប) ថ្ងៃបន្ទាប់ពីមានសេចក្តីសម្រេចតែងតាំងនិងត្រូវជូនដំណឹងក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃ ដល់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនសម្បទានទាំងអស់ឱ្យបានទូលំទូលាយ។

-ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចឬសម្បទានិកទាំងអស់ ត្រូវទទួលខុសត្រូវផ្តល់ព័ត៌មាន និងឯកសារថតចម្លងដែលពាក់ព័ន្ធដល់លេខាធិការដ្ឋានបច្ចេកទេសក្នុងរយៈពេល០៦

(ប្រាំមួយ) ខែ បន្ទាប់ពីការជូនដំណឹងឬការផ្សព្វផ្សាយសេចក្តីជូនដំណឹង ដើម្បីចុះក្នុងសៀវភៅសម្បទានដីសេដ្ឋកិច្ច (មាត្រា៣៧ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច)។

ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដែលមានស្រាប់ ត្រូវអនុវត្តនូវជំហានត្រួតពិនិត្យឡើងវិញតាមស្ថានភាពនៃករណីនីមួយៗដូចខាងក្រោម៖

-ការអនុវត្តរបស់សម្បទានិក ផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យាជាធរមានដោយពិចារណាលើកម្រិតនៃការវិនិយោគដែលបានធ្វើរួចហើយនិងដែលគ្រោងធ្វើបន្ត

-ប្រាក់ចំណូលនិងថ្លៃប្រើប្រាស់ដីតាមកិច្ចសន្យាសម្បទាន

-ធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ចនៅឃុំសង្កាត់ដែលដីសម្បទាននោះស្ថិតនៅ

-ប្រសិនបើសម្បទានិកម្នាក់កាន់កាប់ដីសម្បទានសរុបលើសពី១០.០០០ (មួយម៉ឺន) ហិកតា ត្រូវស្នើឱ្យសម្បទានិកនោះស្ម័គ្រចិត្តកាត់ដីដែលលើសជូនរដ្ឋវិញ ឬប្រសិនបើសម្បទានិកមិនស្ម័គ្រចិត្តកាត់បន្ថយដីសម្បទាននោះទេ ត្រូវព្យាយាមចរចាលើការកាត់បន្ថយ

-ស្នើឱ្យមានការធ្វើនិយ័តកម្មដីនោះ ដូចមានចែងក្នុងមាត្រា៤២ នៃអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច

-យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស លើសេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ

-ក្នុងរយៈពេល០៦ (ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹងស្តីពីការបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវដាក់របាយការណ៍ជូនគណៈរដ្ឋមន្ត្រីដោយភ្ជាប់យោបល់លេខាធិការដ្ឋានបច្ចេកទេសទាក់ទងទៅនឹងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលខ្លួនបានចុះកិច្ចសន្យា ហើយបន្ទាប់មកទៀត របាយការណ៍នេះត្រូវធ្វើឡើងទៀងទាត់រៀងរាល់០៦ (ប្រាំមួយ) ខែម្តង

-នៅក្នុងអំឡុងពេលនិងក្រោយពេលបញ្ចប់ការត្រួតពិនិត្យឡើងវិញ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាត្រូវបន្តការតាមដានការអនុវត្តកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខានិងមិនត្រូវលុបចោលឬមានបញ្ហាឱ្យផ្អាកដំណើរការហើយរាយការណ៍អំពីការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច លើកលែងតែមានសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីផ្ទុយពីនេះ (មាត្រា៣៧ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច)។

នីតិវិធីសម្រាប់ការកាត់បន្ថយទំហំដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ដោយស្ម័គ្រចិត្តឬដោយការចរចាដូចមានចែងក្នុងមាត្រា៥៩ នៃច្បាប់ភូមិបាលឆ្នាំ២០០១ ត្រូវអនុវត្តដូចតទៅ៖

-ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ត្រូវស្នើឱ្យសម្បទានិកស្ម័គ្រចិត្តជ្រើសរើសចំណែកណាមួយនៃដីសម្បទានបង្វិលជូនរដ្ឋវិញ ស្របតាមមាត្រា៤០ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច

-ប្រសិនបើសម្បទានិកមិនមានឆន្ទៈស្ម័គ្រចិត្តកាត់បន្ថយទំហំសម្បទាននោះទេ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវអញ្ជើញសម្បទានិកមកចរចាអំពីផែនការប្រើប្រាស់ដីសម្បទានដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស

-ប្រសិនបើការចរចាមិនសម្រេចបានជោគជ័យនៅក្នុងកំឡុងពេល០៦ (ប្រាំមួយ) ខែ គិតចាប់ពីថ្ងៃចាប់ផ្ដើមការចរចា ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវរាយការណ៍ជូនទៅគណៈរដ្ឋមន្ត្រីតាមរយៈលេខាធិការដ្ឋានបច្ចេកទេសនិង

-ប្រសិនបើសម្បទានិកខកខានមិនបានចូលមកចរចាក្នុងរយៈពេល៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលលិខិតអញ្ជើញឱ្យមកចរចាត្រូវបានបញ្ជូនដល់អាសយដ្ឋានឬដល់ដៃសម្បទានិក ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដើម្បីមានវិធានការ (មាត្រា៣៨ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

គណៈរដ្ឋមន្ត្រីមានសិទ្ធិលើកលែងការកាត់បន្ថយការកាន់កាប់សម្បទានដីសេដ្ឋកិច្ចដែលមានទំហំសរុបលើសពី១០.០០០(មួយម៉ឺន) ហិកតាក្នុងករណីដូចខាងក្រោម៖

-ដីសម្បទាននោះ ត្រូវបានផ្ដល់ឱ្យមុនពេលដែលច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាន

-ការកាត់បន្ថយដីសម្បទាននោះនាំឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការនៅពេលដែលនីតិភូមិបាលឆ្នាំ២០០១ ចូលជាធរមាន។ ការកាប់ឆ្ការដើមឈើឬការផុតព្រៃសំអាតដី មិនត្រូវបានចាត់ទុកជាអាជីវកម្មកំពុងដំណើរការឬជាការបំពេញតាមលក្ខខណ្ឌនៃការអភិវឌ្ឍដីដែលមានចែងក្នុងកិច្ចសន្យាឡើយ (មាត្រា៣៩ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

យោបល់របស់លេខាធិការដ្ឋានបច្ចេកទេសលើសេចក្ដីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ លើសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់នីមួយៗដែលផ្ដល់ជូនទៅក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវបញ្ជាក់សេចក្ដីដូចខាងក្រោម៖

-កិច្ចសន្យានោះកំពុងដំណើរការដោយពេញលេញ

-កិច្ចសន្យានេះ គួរមានការកែប្រែលើចំណុចជាក់លាក់ដោយបញ្ជាក់អំពីកិច្ចការដែលត្រូវបំពេញដោយភាគីនៃកិច្ចសន្យា ដើម្បីទទួលបានទាំងសងខាង

-គួរលុបចោលកិច្ចសន្យានោះ ដោយមូលហេតុសម្បទានិកបានបំពានលើកិច្ចសន្យា

-ចំពោះដីសម្បទានលើសពី១០.០០០(មួយម៉ឺន) ហិកតា ត្រូវបញ្ជាក់អំពីការស្ម័គ្រចិត្តកាត់បន្ថយទំហំដីដោយសម្បទានិកឬត្រូវធ្វើការចរចាដើម្បីកាត់បន្ថយ ឬហេតុផលចាំបាច់សម្រាប់ការលើកលែងការកាត់បន្ថយដីសម្បទាន។

ការជ្រើសរើសដីសម្រាប់កាត់បន្ថយ ត្រូវបញ្ចូលផ្នែកដែលមានទំនាស់ ផ្នែកដែលមិនទាន់បានកាប់ឆ្ការ ផ្នែកដែលជាដីសាធារណៈរបស់រដ្ឋ (មាត្រា៤០ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

របាយការណ៍ត្រួតពិនិត្យ អនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេសនិងលទ្ធផលចុងក្រោយនៃការត្រួតពិនិត្យឡើងវិញលើសម្បទាននីមួយៗ ត្រូវរក្សាទុកជាឯកសារសាធារណៈនៅលេខាធិការដ្ឋានបច្ចេកទេសនិងនៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត (មាត្រា៤១ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

ការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើនិយ័តកម្មដីក្នុងតំបន់ដីសម្បទានដែលជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញ។ ការធ្វើនិយ័តកម្មដីមានរាប់បញ្ចូលការកែតម្រូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លីរបស់អ្នកកាន់កាប់ក្បាលដីក្នុងតំបន់ត្រួតពិនិត្យឡើងវិញនិងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន (មាត្រា៤២ នៃអនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច)។

**ខ- ភារកិច្ចរបស់សម្បទានិកនិងលក្ខខណ្ឌកម្ចាត់ដីសម្បទានសេដ្ឋកិច្ច**

**ខ-១- ភារកិច្ចរបស់សម្បទានិក**

សម្បទានដីសេដ្ឋកិច្ច ជាសិទ្ធិស្របច្បាប់ដែលបានចែងក្នុងឯកសារគតិយុត្តផ្ដល់ដោយអាជ្ញាធរមានសមត្ថកិច្ចតាមអំណាចឆន្ទានុសិទ្ធិឱ្យរូបវន្តបុគ្គលឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បីកាន់កាប់ដីនិងប្រើប្រាស់សិទ្ធិលើដីនោះតាមការកំណត់នៃច្បាប់។ សម្បទានដីសេដ្ឋកិច្ច អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍កាន់កាប់ទាញយកផលដោយធ្វើអាជីវកម្មកសិ-ឧស្សាហកម្មលើដីនៃព្រះរាជាណាចក្រកម្ពុជានិងមិនអាចប្រគល់ឱ្យដោយឥតគិតថ្លៃទេ លើកលែងតែសម្បទានឆ្លើយតបទៅនឹងផលប្រយោជន៍សង្គមដែលប្រគល់ឱ្យគ្រួសារក្រីក្រសម្រាប់តាំងទីលំនៅឬ/និងដាំដំណាំចិញ្ចឹមជីវិត។

សម្បទានដីសេដ្ឋកិច្ច អាចបង្កើតបានសិទ្ធិក្នុងរយៈពេលមួយដែលបានកំណត់ក្នុងកិច្ចសន្យា។ សម្បទានដីសេដ្ឋកិច្ច មិនអាចឈានដល់ការបង្កើតនូវសិទ្ធិជាកម្មសិទ្ធិលើដីដែលបានផ្ដល់ជាសម្បទានជាប្រយោជន៍ដល់សម្បទានិកនោះទេ លើកលែងតែសម្បទានដីដែលឆ្លើយតបទៅនឹងប្រយោជន៍សង្គមពោលគឺ សម្បទានដីសង្គមកិច្ច។ សម្បទានិក មានសិទ្ធិលើដីសម្បទានសេដ្ឋកិច្ចដែលបានផ្ដល់ជាសម្បទានតែនៅក្នុងអំឡុងពេលសម្បទានប៉ុណ្ណោះ។ ពោលគឺ មានសិទ្ធិដូចជាកម្មសិទ្ធិករដែរ លើកលែងតែការផ្ទេរសិទ្ធិ។ ប៉ុន្តែការផ្ទេរដីសម្បទានសេដ្ឋកិច្ចអាចអនុវត្តបានលុះត្រាតែបង្កើតកិច្ចសន្យាថ្មី នៃសម្បទានដោយអាជ្ញាធរមានសមត្ថកិច្ចជាគុណប្រយោជន៍ដល់អ្នកទទួលសិទ្ធិសម្បទានថ្មី។ ប៉ុន្តែករណីសម្បទានិកទទួលមរណភាព ទាយាទទាំងឡាយរបស់សពប្រសិនជាមានបំណង អាចនឹងបន្តប្រើប្រាស់សិទ្ធិទាំងនោះក្នុងរយៈពេលដែលសម្បទាននោះនៅសល់។

សម្បទានិក អាចទាញយកនូវផលិតផលពីដីរបស់ខ្លួនដោយធ្វើការដាំដុះស្របតាមគោលបំណងនៃសម្បទាន។ សម្បទានិកមិនអាចកែប្រែគោលបំណងនៃសម្បទានធ្វើឱ្យប៉ះពាល់ដល់រចនាសម្ព័ន្ធធម្មជាតិនិងធ្វើអាជីវកម្មដែលមានលក្ខណៈជាការបំផ្លាញនៅចុងបញ្ចប់នៃសម្បទានបានឡើយ។

សម្បទានិក មានសិទ្ធិជាពិសេសក្នុងការការពារស្ថានភាពរបស់ខ្លួនដោយអាជ្ញាធរមានសមត្ថកិច្ច។ សម្បទានិក អាចការពារដីដែលបានផ្តល់ជាសម្បទានឱ្យខ្លួនចំពោះការទន្ទ្រានឬការប៉ះពាល់ទោះជារូបភាពណាក៏ដោយ។ កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចគឺ មានរយៈពេលកំណត់ត្រឹម៩៩ (កៅសិបប្រាំបួន) ឆ្នាំយ៉ាងច្រើន (មាត្រា៤៨ មាត្រា៤៩ មាត្រា៥១ មាត្រា៥២ មាត្រា៥៦ និងមាត្រា៥៧ នៃនីតិភូមិបាលឆ្នាំ២០០១)។

**១-២- លក្ខខណ្ឌនៃការដកហូតដីសម្បទានសេដ្ឋកិច្ច**

សម្បទានដីត្រូវមានលក្ខខណ្ឌ។ សម្បទាន ត្រូវតែអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ដែលជាសណ្តាប់ធ្នាប់សាធារណៈ។

លិខិតសម្បទានអាចមានខដោយឡែកផ្សេងទៀតដែលមានតម្លៃជាកិច្ចសន្យា។

សម្បទានដីសេដ្ឋកិច្ច ត្រូវបានដកហូតវិញដោយសេចក្តីសម្រេចខាងរដ្ឋបាល ក្នុងករណីលក្ខខណ្ឌច្បាប់មិនត្រូវបានគោរព។ ករណីនេះ សម្បទានិកមានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីដែលច្បាប់បានកំណត់។ សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានទុកជាមោឃៈដោយតុលាការ កាលបើសម្បទានិកមិនគោរពខដែលមានចែងក្នុងកិច្ចសន្យា។

សម្បទានដីសេដ្ឋកិច្ចសម្រាប់ដំណាំឧស្សាហកម្ម ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល១២ (ដប់ពីរ)ខែបន្ទាប់ពីការផ្តល់សម្បទាន។ ក្នុងករណីមិនអនុវត្តតាមការកំណត់នេះទេ សម្បទានដីត្រូវទុកជាមោឃៈ។

ការខកខានធ្វើអាជីវកម្មរយៈពេលលើសពី១២ (ដប់ពីរ)ខែ នាំឱ្យមោឃភាពសម្បទានសេដ្ឋកិច្ចប្រសិនបើការខកខាននោះពុំមានមូលហេតុត្រឹមត្រូវ។

រាល់សម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់មុននីតិភូមិបាលឆ្នាំ២០០១ ចូលជាធរមាន ហើយមិនបានធ្វើអាជីវកម្មចាប់ពី១២ (ដប់ពីរ) ខែឡើងទៅគិតពីថ្ងៃដែលនីតិភូមិបាលឆ្នាំ២០០១ ចូលជាធរមាន ត្រូវទុកជាមោឃៈប្រសិនបើការខកខាន មិនបានធ្វើអាជីវកម្មនោះពុំមានមូលហេតុត្រឹមត្រូវ។

រាល់ការមិនបានបំពេញកិច្ចតាមសៀវភៅបន្ទុកដោយសម្បទានិកនាំឱ្យមានការដកហូតសម្បទាន។ ក្នុងករណីដកហូតសម្បទាន ទោះជាមានមូលហេតុអ្វីក៏ដោយ សម្បទានិកគ្មានសិទ្ធិទារសំណងនៃការខូចខាតណាមួយឡើយ (មាត្រា៥៤ មាត្រា៥៥ និងមាត្រា៦២ នៃនីតិភូមិបាលឆ្នាំ២០០១)។

ចំពោះកម្មវិធីសម្បទានដីសេដ្ឋកិច្ចដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចប្រគល់ជូនវិនិយោគិន ដើម្បីធ្វើការអភិវឌ្ឍន៍ទៅតាមគម្រោងផែនការរបស់ខ្លួនកន្លងមក គឺមានវិនិយោគិនមួយចំនួនបានអនុវត្តត្រឹមត្រូវទៅតាមគម្រោងផែនការដែលវិនិយោគិនស្នើឡើង ប៉ុន្តែក៏មានវិនិយោគិនមួយចំនួនទៀតពុំបានអនុវត្តទៅតាមគម្រោងផែនការដែលខ្លួនបានស្នើឡើងនោះដែរ។ បញ្ហានេះ នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវបទបញ្ជាមួយស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ចដែលមាន៤ ចំណុច បញ្ជាឱ្យក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីដែលមានសមត្ថកិច្ចពាក់ព័ន្ធអនុវត្តតាមបណ្តាចំណុចមួយចំនួនដូចខាងក្រោម៖

១-ផ្អាកជាបណ្តោះអាសន្ននូវការផ្តល់សម្បទានដីសេដ្ឋកិច្ចចាប់ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ នេះតទៅ

២-ក្រសួង ស្ថាប័ន និងអាជ្ញាធរដែនដីដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវគោលនយោបាយនិងរាល់លក្ខខណ្ឌទាំងឡាយនៃសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ចនិងផ្តោតការយកចិត្តទុកដាក់លើការអនុវត្តកិច្ចសន្យាស្តីពីសម្បទានដីសេដ្ឋកិច្ច ពិសេសគឺការអនុវត្តតាមគោលនយោបាយរូបមន្តស្បែកខ្លានិងការមិនធ្វើឱ្យប៉ះពាល់ដល់ដីធ្លីសហគមន៍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងគោលដៅធ្វើឱ្យសម្បទានដីសេដ្ឋកិច្ចទាំងនេះ បានផ្តល់ផលប្រយោជន៍ពិតប្រាកដជូនប្រទេសជាតិនិងប្រជាជនប្រកបដោយចីរភាព។

៣-ចំពោះក្រុមហ៊ុនដែលបានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលរួចហើយ តែមិនបានអនុវត្តតាមនីតិវិធីជាធរមាននិងតាមកិច្ចសន្យាដោយកាប់ឈើលក់អស់ហើយមិនធ្វើការអភិវឌ្ឍដីសម្បទាន ទន្ទ្រានដីបន្ថែម ទុកដីចោលទំនេរសម្រាប់លក់បន្ត ធ្វើអាជីវកម្មខុសលក្ខខណ្ឌនៃកិច្ចសន្យា បំពានដីរបស់ប្រជាពលរដ្ឋ ឬដីរបស់សហគមន៍ រាជរដ្ឋាភិបាលនឹងដកហូតនូវដីសម្បទានសេដ្ឋកិច្ចទាំងនោះមកវិញ។ សម្បទានសេដ្ឋកិច្ចដែលត្រូវបានដកហូតមកវិញនោះ នឹងត្រូវដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋដោយផ្ទាល់។

៤-ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានទទួលការអនុញ្ញាតជាគោលការណ៍ពីរាជរដ្ឋាភិបាលរួចហើយមុនថ្ងៃចេញបទបញ្ជានេះ ត្រូវបន្តអនុវត្តតាមគោលការណ៍ច្បាប់និងនីតិវិធីជាធរមាន។

សរុបមក គ្រប់វិនិយោគិនដែលទទួលបានការសម្រេចអំពីរាជរដ្ឋាភិបាលលើសម្បទានដីសេដ្ឋកិច្ចរួចហើយ ប៉ុន្តែអនុវត្តផ្ទុយនឹងលក្ខខណ្ឌដូចមានចែងក្នុងកិច្ចសន្យានិងបានធ្វើឱ្យប៉ះពាល់ដីធ្លីសហគមន៍ និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ រាជរដ្ឋាភិបាលនឹងធ្វើការដកហូតសម្បទានដីសេដ្ឋកិច្ចនោះមកវិញ ដើម្បីដាក់ឱ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ។ ប៉ុន្តែនៅក្នុងខ្លឹមសារបទបញ្ជាចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ នេះ គេពុំឃើញមានការដាក់ទណ្ឌកម្ម ឬតម្រូវឱ្យជួសជុលព្យសនកម្មដែលបង្កឡើងដោយវិនិយោគិននោះទេ ប្រសិនបើវិនិយោគិននោះពុំបានអនុវត្តតាមកិច្ចសន្យា។ ប៉ុន្តែមានចំណុចសំខាន់មួយក្នុងបទបញ្ជាគឺ ការផ្អាកបណ្តោះអាសន្នក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចចាប់ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ តទៅ។ ផ្ទុយទៅវិញ រាជរដ្ឋាភិបាលគាំទ្រចំពោះសម្បទានិកដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលមុនថ្ងៃចេញបទបញ្ជានេះ ហើយដែលអនុវត្តបានត្រឹមត្រូវតាមគោលការណ៍និងនីតិវិធីជាធរមាន។

## សន្និដ្ឋាន

សម្បទានដីសេដ្ឋកិច្ច ត្រូវបានបង្កើតឡើងដោយលិខិតគតិយុត្ត។ ឯការសម្រេចផ្តល់សម្បទានដីសេដ្ឋកិច្ចវិញ ជាភារកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចដែលអនុញ្ញាតឱ្យសម្បទានិកចូលមកកាន់កាប់ក្នុងរយៈពេលមួយមានកំណត់។ មានន័យថា សម្បទានដីសេដ្ឋកិច្ចពុំអាចកើតឡើងពីស្ថានភាពកាន់កាប់ដីជាក់ស្តែងរបស់សម្បទានិកបានទេ ពោលគឺត្រូវសំអាងលិខិតគតិយុត្តដែលបានផ្តល់មុនការកាន់កាប់ដី ដោយអាជ្ញាធរមានសមត្ថកិច្ចគឺ រដ្ឋឬសមូហភាពដែនដី

សាធារណៈ ឬគ្រឹះស្ថានសាធារណៈដែលជាកម្មសិទ្ធិករនៃដីដែលត្រូវបានផ្តល់ជាសម្បទាន។ សម្បទានដីសេដ្ឋកិច្ច តាមបញ្ញត្តិមាត្រា៥៣ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ត្រូវតែចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់។

ចំពោះការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចវិញមាន២ យ៉ាងគឺៈ សំណើដែលមានការអំពាវនាវធ្វើដោយអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាដែលជាអ្នកលើកគម្រោងរកវិនិយោគិនឱ្យដាក់សំណើសម្បទានដីសេដ្ឋកិច្ចនិងការស្នើសុំដោយលើកគម្រោងរបស់វិនិយោគិន ដើម្បីសុំការអនុញ្ញាតធ្វើសម្បទានដីសេដ្ឋកិច្ច។

សម្បទានដីសេដ្ឋកិច្ច គឺជាការផ្តល់ដីទៅឱ្យវិនិយោគិនណាមួយដែលមានធនធានគ្រប់គ្រាន់ ដើម្បីធ្វើការវិនិយោគនិងអភិវឌ្ឍន៍តំបន់ណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្បទានដីសេដ្ឋកិច្ចជាប្រភពចំណូលមួយរបស់រដ្ឋនិងបង្កើតការងារជូនប្រជាពលរដ្ឋ។ ប៉ុន្តែសម្បទានដីសេដ្ឋកិច្ចក៏អាចធ្វើឱ្យបាត់បង់កម្លាំងពលកម្មក្នុងស្រុកផងដែរ ប្រសិនបើសកម្មភាពវិនិយោគនោះមានលក្ខណៈបច្ចេកទេសវិទ្យាសាស្ត្រទំនើបអាចប៉ះពាល់បរិស្ថានឬប្រព័ន្ធអេកូឡូស៊ីធនធានធម្មជាតិ និង/ឬសុខភាពសាធារណៈ។

ចំពោះការផ្តល់សម្បទានដីសេដ្ឋកិច្ចផ្អែកតាមខ្លឹមសារមាត្រា១៦ នៃនីតិភូមិបាលឆ្នាំ២០០១ អាចប្រព្រឹត្តទៅបានតែដីដែលជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋប៉ុណ្ណោះ ប៉ុន្តែពុំអាចអនុវត្តសម្បទានដីសេដ្ឋកិច្ចទៅលើដីដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋបានទេ លើកលែងតែធ្វើអនុបយោគដីនេះមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋសិន ទើបអនុវត្តកម្មវិធីសម្បទានដីសេដ្ឋកិច្ចបាន។ ជាក់ស្តែង មាត្រា៥៨ នៃនីតិភូមិបាលឆ្នាំ២០០១ បានបញ្ញត្តិថា:"***សម្បទានដី អាចធ្វើឡើងបានតែនៅលើដីដែលជាចំណែកនៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ***។"

ចំពោះការធ្វើអនុបយោគវិញ បញ្ញត្តិមាត្រា១៦ នៃនីតិភូមិបាលឆ្នាំ២០០១ និងមាត្រា១៤ នៃអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋឆ្នាំ២០០៥ បានកំណត់ថាៈ ការធ្វើអនុបយោគពីទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ ត្រូវរៀបចំច្បាប់អនុបយោគសម្រាប់ប្រើប្រាស់ជាផ្លូវការ។ ប៉ុន្តែស្ថានភាពចំពោះមុខក៏ដូចជាសេចក្តីត្រូវការបន្ទាន់និងចាំបាច់ផងនោះ រាជរដ្ឋាភិបាលកម្ពុជាក៏បានដាក់ចេញនូវព្រះរាជក្រឹត្យលេខ រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៨ខែសីហាឆ្នាំ២០០៦ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈមួយឡើង ដើម្បីបំពេញសេចក្តីត្រូវការបណ្តោះអាសន្នរហូតមានច្បាប់អនុបយោគ។ មាត្រា៥ នៃព្រះរាជក្រឹត្យឆ្នាំ២០០៦ បានបញ្ញត្តិ ថា:"***រាជរដ្ឋាភិបាល សម្រេចធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈដោយអនុក្រឹត្យ***" ។ ហេតុនេះហើយ ទើបការប្តូរទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋនោះ រាជរដ្ឋាភិបាលតែងធ្វើអនុបយោគដោយអនុក្រឹត្យ។

ចំពោះការធ្វើសម្បទានដីសេដ្ឋកិច្ចនៅក្នុងដែននេសាទដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ អាចអនុវត្តទៅបាន លុះត្រាដែននេសាទឬផ្នែកណាមួយនៃដែននេសាទនោះឈប់បម្រើផលប្រយោជន៍សាធារណៈឬវិស័យជល

ផលជាអាទិ៍ ដែននេសាទទាំងនោះ ត្រូវបានគោករឹងរាក់ហើយពុំអាចស្តារឡើងវិញបាន ប៉ុន្តែដែននេសាទនេះបានទៅបម្រើវិស័យផ្សេងវិញដូចជា ធ្វើកសិកម្ម ស្រែ ចំការ ដាំដំណាំ ចិញ្ចឹមសត្វ សិប្បកម្ម ឬបម្រើឱ្យការសាងសង់សំណង់ផ្សេងៗ តម្រូវឱ្យរាជរដ្ឋាភិបាលធ្វើអនុបយោគដែននេសាទនោះមកជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតាមរយៈអនុក្រឹត្យស្របតាមខ្លឹមសារមាត្រា៥ នៃព្រះរាជក្រឹត្យឆ្នាំ២០០៥ ប៉ុន្តែការសម្រេចរបស់រាជរដ្ឋាភិបាលនេះ ត្រូវតែសម្រេចតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កឋាខណ្ឌទី២ មាត្រា៩ នៃនីតិជលផលឆ្នាំ២០០៦ បានបញ្ញត្តិថា:"*រាល់ការប្រើប្រាស់ដែននេសាទ ដើម្បីគោលបំណងក្រៅពីវិស័យជលផលត្រូវមានការសម្រេចពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។*"

ចំពោះការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទកន្លងមក ក៏មានការអនុវត្តច្រើនដែរតាមរយៈការដាក់សំណើអំពីវិនិយោគិនដោយពុំមានការអំពាវនាវអំពីរដ្ឋឡើយ។ ឯការសម្រេចលើសម្បទានដីសេដ្ឋកិច្ចនិងការអនុវត្តនីតិវិធីនោះ ក៏ពុំទាន់អនុវត្តត្រឹមត្រូវតាមនីតិវិធីជាធរមានដែរ។ ជាក់ស្តែង ការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទជូនដល់ក្រុមហ៊ុនមួយចំនួនកន្លងមក គឺរដ្ឋាភិបាលសម្រេចត្រឹមតែសេចក្តីជូនដំណឹង (<u>សជណ</u>) របស់ទីស្តីការគណៈរដ្ឋមន្ត្រីប៉ុណ្ណោះ។

ចំពោះការផ្តល់សម្បទានដីសេដ្ឋកិច្ចចាប់ពីឆ្នាំ១៩៩៦ មកដល់បច្ចុប្បន្ន អាជ្ញាធរកាន់កាប់ដីរដ្ឋ (ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ) បានផ្តល់សម្បទានដីសេដ្ឋកិច្ចនៅលើដែនព្រៃឈើនិងដែននេសាទ ជូនវិនិយោគិនជាតិនិងបរទេសបានចំនួន១១៧ ក្រុមហ៊ុនស្មើនឹងផ្ទៃដីទំហំសរុប១,១៨ លាន ហិកតារួចហើយ ក្នុងនោះរួមមាន ក្រុមហ៊ុនជាតិចំនួន៣៩ ស្មើនឹងផ្ទៃដីទំហំ៥៩៣.០០០ហិកតា និងក្រុមហ៊ុនបរទេសចំនួន៧៨ ក្នុងនោះរួមមាន ក្រុមហ៊ុនវៀតណាមចំនួន៣១ ស្មើនឹងផ្ទៃដីទំហំ២៣១.០០០ ហិកតា ក្រុមហ៊ុនចិនចំនួន២៥ ស្មើនឹងផ្ទៃដីទំហំ១៩៣.០០០ ហិកតា ក្រុមហ៊ុនសាធារណរដ្ឋកូរ៉េចំនួន៥ ស្មើនឹងផ្ទៃដីទំហំ៣៧.០០០ ហិកតា ក្រុមហ៊ុនថៃចំនួន៥ ស្មើនឹងផ្ទៃដីទំហំ៣៨.០០០ ហិកតា ក្រុមហ៊ុនអាមេរិកចំនួន២ ស្មើនឹងផ្ទៃដីទំហំ១៩.០០០ ហិកតា ក្រុមហ៊ុនឥណ្ឌាចំនួន៣ ស្មើនឹងផ្ទៃដីទំហំ១៧.០០០ ហិកតា ក្រុមហ៊ុនម៉ាឡេស៊ីចំនួន៣ ស្មើនឹងផ្ទៃដីទំហំ២៣.០០០ ហិកតា ក្រុមហ៊ុនអូស្ត្រាលីចំនួន១ ស្មើនឹងផ្ទៃដីទំហំ៨.៩៧៧ ហិកតា និងក្រុមហ៊ុនស៊ុយអ៊ែតចំនួន១ ក្រុមហ៊ុនសិង្ហបុរីចំនួន១ និងក្រុមហ៊ុនអ៊ីស្រាអែលចំនួន១ ប៉ុន្តែក្រុមហ៊ុនទ៣ ក្រោយនេះ គឺពុំមានបញ្ជាក់ទំហំផ្ទៃដីសម្បទានទេ (ប្រសាសន៍របស់ **ឯកឧត្តម ចន្ទ សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កាលពីព្រឹកថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៣ ក្នុងកិច្ចប្រជុំពេញអង្គនៃរដ្ឋសភាជាតិក្នុងឱកាសការពារសេចក្តីព្រាងច្បាប់ស្តីពីសហគមន៍កសិកម្ម)។

ជាទីបញ្ចប់ ស្នេរនិពន្ធទាំងទ្វេសូមបញ្ជូនឯកសារស្រាវជ្រាវនេះ ជូនដល់មិត្តអ្នកអានទាំងអស់ ជាពិសេសអ្នកដែលមានបំណងស្វែងយល់អំពីកម្មវិធីសម្បទានដីសេដ្ឋកិច្ចនៅលើទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងនីតិវិធីជាធរមានក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទ និងក៏ជាសារមួយជូនដល់មន្ត្រីរដ្ឋបាលជលផលមានសមត្ថកិច្ច

ទាំងអស់ផងដែរ ដើម្បីធ្វើជាមូលដ្ឋានគតិយុត្តក្នុងការការពារ គ្រប់គ្រង និងថែរក្សាដែននេសាទបានគង់វង្សសម្រាប់កូនចៅគ្រប់ជំនាន់ ជាពិសេសបានរួចផុតពីការចូលទន្ទ្រានកាន់កាប់ដោយខុសច្បាប់ឬការអនុវត្តពុំត្រឹមត្រូវតាមនីតិវិធីនូវការផ្តល់សម្បទានដីសេដ្ឋកិច្ចក្នុងដែននេសាទដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ៕

## ឯកសារយោងៈ

### ក-ផ្នែកឯកសារ

-ប្រវត្តិនៃការគ្រប់គ្រងវិស័យជលផលនៅព្រះរាជាណាចក្រកម្ពុជារបស់ **ឯកឧត្តម ណៅ ធួក** និងលោក **ប៉ូ សេងជី** ឆ្នាំ២០០៧

-និនានុលេខន៍ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១២

-សារណាបញ្ចប់ការសិក្សារបស់និស្សិត **តន់ ស្រីចន្ថា អ៊ុច សីហា ណាប់ សុម៉ាលី** ស្តីពីការប្រៀបធៀបសម្បទានដីសេដ្ឋកិច្ចនិងសង្គមកិច្ច ឆ្នាំ២០០៧

-នីតិរដ្ឋបាលនៃទ្រព្យសម្បត្តិសាធារណៈរបស់បណ្ឌិត **ស៊ុ សុជាតិ** ឆ្នាំ២០០៧។

### ខ-ផ្នែកបទដ្ឋានគតិយុត្ត

-ច្បាប់ភូមិបាល ឆ្នាំ២០០១

-ច្បាប់ស្តីពីជលផល ឆ្នាំ២០០៦

-ព្រះរាជក្រឹត្យលេខ នស/រកត/០៨០៦/៣៣៩ ស្តីពីគោលការណ៍និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ ឆ្នាំ២០០៦

-អនុក្រឹត្យលេខ១៤៦ អនក្រ ស្តីពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥

-អនុក្រឹត្យលេខ១១៨ អនក្រ ស្តីពីការគ្រប់គ្រងដីរដ្ឋ ឆ្នាំ២០០៥

-អនុក្រឹត្យលេខ២៥ អនក្រ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ឆ្នាំ២០០៧

-បទបញ្ជាលេខ០១ បប ចុះថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១២ ស្តីពីវិធានការពង្រឹងនិងបង្កើនប្រសិទ្ធភាពនៃការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០១២។

បោះពុម្ពលើកទី១ ចំនួន ១.០០០ ក្បាល
ឧបត្ថម្ភដោយ៖ **អង្គការសម្ព័ន្ធភាព ដើម្បីអភិរក្សធនធានជលផល (FACT)**

**រក្សាសិទ្ធិគ្រប់យ៉ាង**